# បដិច្ចសមុប្បាទ

## និង

# ឥទប្បច្ចយតា

រៀបរៀងដោយ

ភិក្ខុ ខិន គេន ឥន្ទបញ្ញោ

វត្តពោធិវង្ស ប្រទេសបារាំង

បោះពុម្ពចែកជាធម្មទាន

លើកទី ១ ចំនួន ១៥០០ ក្បាល

# បដិច្ចសមុប្បាទ
និង
# ឥទប្បច្ចយតា

រៀបរៀងដោយ
**ភិក្ខុ ខិន ភេន ឥន្ទប្បញ្ញោ**
វាយកុំព្យូទ័រ និង ចាត់ចែងដោយ
ភិក្ខុ ពេជ្រ សាម៉ុន ចិរវឌ្ឍោ

បោះពុម្ពចែកជាធម្មទាន
លើកទី ១ ចំនួន ១៥០០ ក្បាល
ដោយពុទ្ធបរិស័ទ វត្តពោធិវង្ស
ប្រទេសបារាំង

ព.ស. ២៥៥៥ គ.ស. ២០១១

# អារម្ភកថា

១❋៩

ខ្ញុំមិនមានគម្រោង នឹងសរសេរ បដិច្ចសមុប្បាទ ទេ ប៉ុន្តែ ដោយបានឃើញសៀវភៅ បដិច្ចសមុប្បាទ របស់គេ ទឹកឃើញដល់រឿងមួយ ដែលលោក អ្នកប្រាជ្ញខ្លះ លោកមិនយល់ស្រប តាមសេចក្តីអធិប្បាយ បដិច្ចសមុប្បាទ បែបតៗគ្នា (មិនសូវប្រើបញ្ញា... ) ។

ខ្ញុំ ព្រារព្ធដល់ចំណុចនោះបន្តិច ទើបប្រមូលរៀបរៀងជាកូនសៀវភៅ បដិច្ចសមុប្បាទ និង ឥទប្បច្ចយតា នេះឡើង ។ ខ្ញុំសង្ឃឹមថា កូនសៀវភៅនេះ នឹងបានជាប្រយោជន៍ខ្លះ ដល់លោកអ្នក អាន ជាពុំខាន ៕

វត្តពោធិវង្ស ថ្ងៃទី ០៨ ខែកញ្ញា ឆ្នាំ ២០១១

ភិក្ខុ ខិន ភេន

# នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស
# វិនយបិដក មហាវគ្គ

## មហាខន្ធក

(១) សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ ទើបនឹងបាន ត្រាស់ដឹងថ្មី ៗ ទ្រង់គង់ទៀបគល់ពោធិព្រឹក្ស ក្បែរឆ្នេរស្ទឹងនេរញ្ជរា ក្នុងឧរុវេលប្រទេស ។ គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់គង់ ដោយព្រះភ្នែនតែមួយ សោយវិមុត្តិសុខ អស់ ៧ ថ្ងៃ ក្បែរគល់ ពោធិព្រឹក្ស ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់មនសិការ (ពិចារណា) បដិច្ចសមុប្បាទ ជា អនុលោម បដិលោម អស់ បឋមយាមនៃរាត្រី ដូច្នេះ :

បដិច្ចសមុប្បាទ អនុលោម[១]

**អវិជ្ជាបច្ចយា** **សង្ខារា**

---

[១]- សម័យដំបូង បដិច្ចសមុប្បាទ នាំឲ្យកើត ហៅថា អនុលោម នាំឲ្យរលត់ ហៅថា បដិលោម ។ សម័យក្រោយមក បដិច្ចសមុប្បាទ នាំឲ្យកើត ហៅថា សមុទយវារៈ នាំឲ្យរលត់ ហៅថា និរោធវារៈ ។ បដិច្ចសមុប្បាទ និយាយពី អវិជ្ជា ចុះទៅរក ជាតិ ជរាមរណៈ ហៅថា អនុលោម និយាយពី ជាតិ ជរាមរណៈ ឡើងមករក អវិជ្ជា ហៅថា បដិលោម ។

| | |
|---|---|
| សង្ខារបច្ចយា | វិញ្ញាណំ |
| វិញ្ញាណបច្ចយា | នាមរូបំ |
| នាមរូបបច្ចយា | សឡាយតនំ |
| សឡាយតនបច្ចយា | ផស្សោ |
| ផស្សបច្ចយា | វេទនា |
| វេទនាបច្ចយា | តណ្ហា |
| តណ្ហាបច្ចយា | ឧបាទានំ |
| ឧបាទានបច្ចយា | ភវោ |
| ភវបច្ចយា | ជាតិ |

ជាតិបច្ចយា ជរាមរណំ សោកបរិទេវទុក្ខទោមនស្សុបាយាសា សម្ភវន្តិ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។

| | |
|---|---|
| ព្រោះអវិជ្ជាជាបច្ច័យ | ទើបមានសង្ខារ |
| ព្រោះសង្ខារជាបច្ច័យ | ទើបមានវិញ្ញាណ |
| ព្រោះវិញ្ញាណជាបច្ច័យ | ទើបមាននាមរូប |
| ព្រោះនាមរូបជាបច្ច័យ | ទើបមានសឡាយតនះ |
| ព្រោះសឡាយតនះជាបច្ច័យ | ទើបមានផស្សះ |
| ព្រោះផស្សះជាបច្ច័យ | ទើបមានវេទនា |
| ព្រោះវេទនាជាបច្ច័យ | ទើបមានតណ្ហា |

ព្រោះតណ្ហាជាបច្ច័យ ទើបមានឧបាទាន
ព្រោះឧបាទានជាបច្ច័យ ទើបមានភព
ព្រោះភពជាបច្ច័យ ទើបមានជាតិ

ព្រោះជាតិជាបច្ច័យ ទើបមាន ជរាមរណៈ សោកៈ បរិទេវៈ ទុក្ខៈ ទោមនស្សៈ ឧបាយាសៈ សេចក្តីកើតឡើងនៃកងទុក្ខទាំង-អស់នុ៎ះ រមែងមានដោយប្រការដូច្នេះ ។

បដិច្ចសមុប្បាទ បដិលោម

**អវិជ្ជាយ ត្វេវ អសេសវិរាគនិរោធា សង្ខារនិរោធោ**
**សង្ខារនិរោធា វិញ្ញាណនិរោធោ**
**វិញ្ញាណនិរោធា នាមរូបនិរោធោ**
**នាមរូបនិរោធា សឡាយតននិរោធោ**
**សឡាយតននិរោធា ផស្សនិរោធោ**
**ផស្សនិរោធា វេទនានិរោធោ**
**វេទនានិរោធា តណ្ហានិរោធោ**
**តណ្ហានិរោធា ឧបាទាននិរោធោ**
**ឧបាទាននិរោធា ភវនិរោធោ**
**ភវនិរោធា ជាតិនិរោធោ**

**ជាតិនិរោធា ជរាមរណំ សោកបរិទេវទុក្ខទោមនស្សុបាយាសា និរុជ្ឈន្តិ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស និរោធោ ហោតិ ។**

ម្យ៉ាងទៀត ព្រោះអវិជ្ជានេះឯង រលាយ និង រលត់ដោយមិនមានសេសសល់ ទើបសង្ខាររលត់

ព្រោះសង្ខាររលត់ ទើបវិញ្ញាណរលត់
ព្រោះវិញ្ញាណរលត់ ទើបនាមរូបរលត់
ព្រោះនាមរូបរលត់ ទើបសឡាយតនៈរលត់
ព្រោះសឡាយតនៈរលត់ ទើបផស្សៈរលត់
ព្រោះផស្សៈរលត់ ទើបវេទនារលត់
ព្រោះវេទនារលត់ ទើបតណ្ហារលត់
ព្រោះតណ្ហារលត់ ទើបឧបាទានរលត់
ព្រោះឧបាទានរលត់ ទើបភពរលត់
ព្រោះភពរលត់ ទើបជាតិរលត់

ព្រោះជាតិរលត់ ទើបជរាមរណៈ សោកៈ បរិទេវៈ ទុក្ខៈ ទោមនស្សៈ ឧបាយាសៈ រលត់ សេចក្ដីរលត់នៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយប្រការដូច្នេះ[២] ។

<u>**កំណត់ចំណាំ**</u> ព្រះមានព្រះភាគ ទ្រង់មនសិការបដិច្ចសមុប្បាទ ជាអនុលោម បដិលោម មិនមែនតែអស់បឋមយាមនៃរាត្រីប៉ុណ្ណោះទេ អស់មជ្ឈិមយាមនៃរាត្រីផង អស់បច្ឆិមយាមនៃរាត្រីផង គឺ អស់រាត្រីទាំងមូលតែម្ដង ។ ព្រោះអ្វី ?

---

(២)- វិនយបិដក មហាវគ្គ ៦-១-១

ព្រោះធម៌ដែលព្រះអង្គបានត្រាស់ដឹងហើយ

-**គម្ភីរោ** ជាធម៌ជ្រាលជ្រៅ

-**ទុទ្ទសោ** ជាធម៌ឃើញបានដោយកម្រ

-**ទុរនុពោធោ** ជាធម៌ដឹងតាមបានដោយកម្រ

-**សន្តោ** ជាធម៌ស្ងប់

-**បណីតោ** ជាធម៌ប្រណីត

-**និបុណោ** ជាធម៌ល្អិត

-**បណ្ឌិតវេទនិយោ** ជាធម៌ជាវិស័យដែលបណ្ឌិតគប្បីដឹង ។

## សុត្តន្តបិដក

## សំយុត្តនិកាយ និទានវគ្គ អភិសមយសំយុត្ត

## ពុទ្ធវគ្គ

(១) ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន ជាអារាមរបស់ អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ ព្រះមានព្រះភាគ ត្រាស់សំដែងបដិច្ចសមុប្បាទ ដល់ភិក្ខុទាំងឡាយ មានអត្ថន័យដូចដែលបានកត់ទុក ក្នុងព្រះវិន័យខាងដើមនោះដែរ ។ ប៉ុន្តែ ក្នុងគម្ពីរនេះ មានសេចក្តី អធិប្បាយដូចតទៅនេះ :

១-ម្នាលភិក្ខុទាំងឡាយ ចុះអវិជ្ជា តើដូចម្ដេច ម្នាលភិក្ខុទាំងឡាយ សេចក្ដីមិនដឹងក្នុងទុក្ខ ១ សេចក្ដីមិនដឹងក្នុងហេតុជាទីកើតទុក្ខ ១ សេចក្ដីមិនដឹងក្នុងទីរលត់ទុក្ខ ១ សេចក្ដីមិនដឹងក្នុងបដិបទា ជាដំណើរទៅកាន់ទីរលត់ទុក្ខ ១ ម្នាលភិក្ខុទាំងឡាយ នេះ ហៅថា អវិជ្ជា ។

២-ម្នាលភិក្ខុទាំងឡាយ ចុះសង្ខារ តើដូចម្ដេច ម្នាលភិក្ខុទាំងឡាយ សង្ខារនេះមាន ៣ គឺ កាយសង្ខារ ១ វចីសង្ខារ ១ ចិត្តសង្ខារ ១ ម្នាលភិក្ខុទាំងឡាយ នេះ ហៅថា សង្ខារ ។

៣-ម្នាលភិក្ខុទាំងឡាយ ចុះវិញ្ញាណ តើដូចម្ដេច ម្នាល-ភិក្ខុទាំងឡាយ ពួកវិញ្ញាណនេះមាន ៦ គឺ ចក្ខុវិញ្ញាណ ១ សោត-វិញ្ញាណ ១ ឃានវិញ្ញាណ ១ ជិវ្ហាវិញ្ញាណ ១ កាយវិញ្ញាណ ១ មនោវិញ្ញាណ ១ ម្នាលភិក្ខុទាំងឡាយ នេះហៅថា វិញ្ញាណ ។

៤-ម្នាលភិក្ខុទាំងឡាយ ចុះនាមរូប តើដូចម្ដេច ។ វេទនា ១ សញ្ញា ១ ចេតនា ១ ផស្សៈ ១ មនសិការៈ ១ នេះ ហៅថា នាម ។ មហាភូតរូប ៤ និង ឧបាទាយរូប របស់មហា-ភូតរូប ៤ នេះ ហៅថា រូប ។ ម្នាលភិក្ខុទាំងឡាយ នាមនេះផង រូបនេះផង នេះហៅថា នាមរូប ដោយប្រការដូច្នេះ ។

៥-ម្នាលភិក្ខុទាំងឡាយ ចុះអាយតនៈ ៦ តើដូចម្ដេច ។ ចក្ខាយតនៈ ១ សោតាយតនៈ ១ ឃានាយតនៈ ១ ជិវ្ហាយតនៈ ១

កាយាយតនៈ ១ មនាយតនៈ ១ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អាយតនៈ ៦ ។

៦-ម្នាលភិក្ខុទាំងឡាយ ចុះផស្សៈ តើដូចម្ដេច ។ ម្នាល-ភិក្ខុទាំងឡាយ ពួកផស្សៈនេះមាន ៦ គឺ ចក្ខុសម្ផស្ស ១ សោត-សម្ផស្ស ១ ឃានសម្ផស្ស ១ ជីវ្ហាសម្ផស្ស ១ កាយសម្ផស្ស ១ មនោសម្ផស្ស ១ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ផស្សៈ ។

៧-ម្នាលភិក្ខុទាំងឡាយ ចុះវេទនា តើដូចម្ដេច ។ ម្នាល-ភិក្ខុទាំងឡាយ ពួកវេទនានេះមាន ៦ គឺ វេទនាកើតអំពី ចក្ខុ-សម្ផស្ស ១ វេទនាកើតអំពីសោតសម្ផស្ស ១ វេទនាកើតអំពីឃាន-សម្ផស្ស ១ វេទនាកើតអំពីជីវ្ហាសម្ផស្ស ១ វេទនាកើតអំពីកាយ-សម្ផស្ស ១ វេទនាកើតអំពីមនោសម្ផស្ស ១ ម្នាលភិក្ខុទាំងឡាយ នេះហៅថា វេទនា ។

៨-ម្នាលភិក្ខុទាំងឡាយ ចុះតណ្ហា តើដូចម្ដេច ។ ម្នាល ភិក្ខុទាំងឡាយ ពួកតណ្ហានេះមាន ៦ គឺ រូបតណ្ហា ១ សទ្ទតណ្ហា ១ គន្ធតណ្ហា ១ រសតណ្ហា ១ ផោដ្ឋព្វតណ្ហា ១ ធម្មតណ្ហា ១ ម្នាល ភិក្ខុទាំងឡាយ នេះហៅថា តណ្ហា ។

៩-ម្នាលភិក្ខុទាំងឡាយ ចុះឧបាទាន តើដូចម្ដេច ។ ម្នាល ភិក្ខុទាំងឡាយ ឧបាទាននេះ មាន ៤ គឺ កាមុបាទាន ១ ទិដ្ឋុ-បាទាន ១ សីលព្វតុបាទាន ១ អត្តវាទុបាទាន ១ ម្នាលភិក្ខុទាំង-

ឡាយ នេះហៅថា ឧបាទាន ។

១០-ម្នាលភិក្ខុទាំងឡាយ ចុះភព តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភពនេះ មាន ៣ គឺ កាមភព១ រូបភព១ អរូបភព១ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ភព ។

១១-ម្នាលភិក្ខុទាំងឡាយ ចុះជាតិ តើដូចម្តេច ។ កិរិយាកើតជាដំបូង កិរិយាកើតព្រម កិរិយាចុះចាប់ផ្ទៃ កិរិយាកើត កិរិយាវិលត្រឡប់មកកើត កិរិយាកើតប្រាកដនៃខន្ធទាំងឡាយ កិរិយាបាននូវអាយតនៈ ណា របស់សត្វទាំងឡាយនោះ ៗ ក្នុងសត្តនិកាយនោះ ៗ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ជាតិ ។

១២-ម្នាលភិក្ខុទាំងឡាយ ចុះជរា និង មរណៈ តើដូចម្តេច សេចក្តីគ្រាំគ្រា ភាពគ្រាំគ្រា ធ្មេញបាក់ សក់ស្កូវ ស្បែកជ្រួញជ្រីវ ដំណើរថយនៃអាយុ ដំណើរចាស់ទុំនៃឥន្ទ្រីយទាំងឡាយ ណា របស់សត្វទាំងឡាយនោះ ៗ ក្នុងសត្តនិកាយនោះ ៗ នេះហៅថា ជរា ។ ម្នាលភិក្ខុទាំងឡាយ ចុះមរណៈ តើដូចម្តេច ។ ចុតិ ការឃ្លាត ការបែកធ្លាយ ការបាត់ទៅ សេចក្តីស្លាប់ ដំណើរងាប់ ការធ្វើមរណកាល ការបែកធ្លាយនៃខន្ធទាំងឡាយ ការដាក់ចុះនូវសាកសព ការដាច់នៃជីវិតិន្ទ្រីយ ណា របស់សត្វទាំងឡាយនោះៗ ចាកសត្តនិកាយនោះៗ នេះហៅថា មរណៈ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ជរានេះផង មរណៈនេះផង នេះហៅថា

ជរា និង មរណៈ[៣] ។

# អភិធម្មបិដក

## បច្ចយាការវិភង្គ

៣៥៨

ក្នុងគម្ពីរនេះ មាននិយាយរឿង បដិច្ចសមុប្បាទ ព្រមទាំងមានអធិប្បាយគោលសេចក្ដី ដូចក្នុងសុត្តន្តបិដកដែរ ប៉ុន្តែ មានប្លែកគ្នាខ្លះ ។ ខ្ញុំស្រង់យកមកចំពោះត្រង់កន្លែងដែលប្លែកគ្នា ដូចតទៅនេះ :

១-សង្ខារទាំងឡាយ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ តើដូចម្ដេច ។ បុញ្ញាភិសង្ខារ អបុញ្ញាភិសង្ខារ អានេញ្ជាភិសង្ខារ កាយសង្ខារ វចីសង្ខារ ចិត្តសង្ខារ ។ បណ្ដាសង្ខារទាំងនោះ បុញ្ញាភិសង្ខារ តើដូចម្ដេច ។ ចេតនា ជាកុសល ជាកាមាវចរ និងរូបាវចរ ដែលសម្រេចដោយទាន សម្រេចដោយសីល សម្រេចដោយភាវនា នេះហៅថា បុញ្ញាភិសង្ខារ ។ បណ្ដាសង្ខារទាំងនោះ អបុញ្ញាភិសង្ខារ តើដូចម្ដេច។ ចេតនាជាអកុសល ជាកាមាវចរ នេះហៅថា អបុញ្ញាភិសង្ខារ ។ បណ្ដាសង្ខារទាំងនោះ អានេញ្ជាភិសង្ខារ តើដូចម្ដេច។ ចេតនាជាកុសល ជាអរូបាវចរ នេះហៅថា អានេញ្ជាភិសង្ខារ ។ បណ្ដាសង្ខារទាំងនោះ កាយ-

---

[៣]- សុត្តន្តបិដក សំយុត្តនិកាយ និទានវគ្គ ៣១-០១-០១

សង្ខារ តើដូចម្តេច ។ កាយសញ្ចេតនា ឈ្មោះថា កាយសង្ខារ វចីសញ្ចេតនា ឈ្មោះថា វចីសង្ខារ មនោសញ្ចេតនា ឈ្មោះថា ចិត្តសង្ខារ ។ ធម៌ទាំងនេះ ហៅថា សង្ខារទាំងឡាយ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ ។

២-ភព កើតមាន ព្រោះឧបាទានជាបច្ច័យ តើដូចម្តេច ។ ភព មាន ២ គឺ កម្មភពក៏មាន ឧបបត្តិភពក៏មាន ។ បណ្តាភព ទាំងនោះ កម្មភព តើដូចម្តេច ។ បុញ្ញាភិសង្ខារ អបុញ្ញាភិសង្ខារ អានេញ្ជាភិសង្ខារ នេះហៅថា កម្មភព សូម្បីកម្មទាំងអស់ ដែល ជាដំណើរទៅកាន់ភព ក៏ឈ្មោះថា កម្មភពដែរ ។ បណ្តាភព ទាំងនោះ ឧបបត្តិភព តើដូចម្តេច ។ កាមភព រូបភព អរូបភព សញ្ញាភព អសញ្ញាភព នេវសញ្ញានាសញ្ញាភព ឯកវោការភព ចតុវោការភព បញ្ចវោការភព នេះហៅថា ឧបបត្តិភព ។ កម្ម ភពនេះផង ឧបបត្តិភពនេះផង នេះហៅថា ភព កើតមាន ព្រោះឧបាទានជាបច្ច័យ ដោយប្រការដូច្នេះ ។

៣-សោកៈ តើដូចម្តេច ។ សេចក្តីសោក អាការសោក ភាពនៃសេចក្តីសោក ការស្ងួតស្ងប់ខាងក្នុង ការក្រៀមក្រំខាងក្នុង ការជ្រប់ស្រពោននៃចិត្ត ការតូចចិត្ត សរគឺសេចក្តីសោករបស់ បុគ្គលដែលត្រូវសេចក្តីវិនាសញាតិប៉ះពាល់ក្តី ត្រូវសេចក្តីវិនាស ភោគៈប៉ះពាល់ក្តី ត្រូវសេចក្តីវិនាសគឺរោគប៉ះពាល់ក្តី ត្រូវសេចក្តី

វិនាសសីលប៉ះពាល់ក្តី ត្រូវសេចក្តីវិនាសគឺទិដ្ឋិប៉ះពាល់ក្តី ឬប្រកបដោយសេចក្តីវិនាសណាមួយ ឬត្រូវទុក្ខធម៌ណាមួយប៉ះពាល់ហើយ នេះហៅថា សោកៈ ។

៤-បរិទេវៈ តើដូចម្តេច ។ សេចក្តីខ្សឹកខ្សួល ការទួញយំ អាការខ្សឹកខ្សួល អាការទួញយំ ភាពខ្សឹកខ្សួល ភាពទួញយំ ការពោល ការយំរៀបរាប់ ការយំអណ្តឺតអណ្តក ការពោលដែលៗ អាការពោលដែលៗ ភាពពោលដដែលៗ របស់បុគ្គលដែលត្រូវសេចក្តីវិនាសញាតិប៉ះពាល់ក្តី ត្រូវសេចក្តីវិនាសភោគៈប៉ះពាល់ក្តី ត្រូវសេចក្តីវិនាសគឺរោគប៉ះពាល់ក្តី ត្រូវសេចក្តីវិនាសសីល ប៉ះពាល់ក្តី ត្រូវសេចក្តីវិនាសគឺទិដ្ឋិប៉ះពាល់ក្តី ឬ ប្រកបដោយសេចក្តីវិនាសណាមួយ ឬត្រូវទុក្ខធម៌ណាមួយប៉ះពាល់ហើយ នេះហៅថា បរិទេវៈ ។

៥-ទុក្ខៈ តើដូចម្តេច ។ សេចក្តីមិនត្រេកអរប្រព្រឹត្តទៅក្នុងកាយ ទុក្ខប្រព្រឹត្តទៅក្នុងកាយ ការទទួលអារម្មណ៍មិនជាទីត្រេកអរដែលកើតអំពីកាយសម្ផស្ស វេទនាមិនជាទីត្រេកអរ ជាទុក្ខដែលកើតអំពីកាយសម្ផស្ស ណា នេះហៅថា ទុក្ខ ។

៦-ទោមនស្ស តើដូចម្តេច ។ សេចក្តីមិនត្រេកអរប្រព្រឹត្តទៅក្នុងចិត្ត ទុក្ខប្រព្រឹត្តទៅក្នុងចិត្ត ការទទួលអារម្មណ៍មិនជាទី-ត្រេកអរ ជាទុក្ខដែលកើតអំពីចេតោសម្ផស្ស វេទនាមិនជាទីត្រេក

អរ ជាទុក្ខដែលកើតអំពីចេតោសម្ផស្ស ណា នេះ ហៅថា ទោមនស្ស ។

៧-ឧបាយាសៈ តើដូចម្តេច ។ សេចក្តីតានតឹងចិត្ត ភាពតានតឹងចិត្ត ភាពចង្អៀតចង្អល់ចិត្ត របស់បុគ្គលដែលត្រូវសេចក្តីវិនាសញាតិប៉ះពាល់ក្តី ត្រូវសេចក្តីវិនាសភោគៈប៉ះពាល់ក្តី ត្រូវសេចក្តីវិនាសគឺរោគប៉ះពាល់ក្តី ត្រូវសេចក្តីវិនាសសីលប៉ះពាល់ក្តី ត្រូវសេចក្តីវិនាសគឺទិដ្ឋិប៉ះពាល់ក្តី ឬ ប្រកបដោយសេចក្តីវិនាសណាមួយ ឬត្រូវទុក្ខធម៌ណាមួយប៉ះពាល់ហើយ នេះហៅថា ឧបាយាសៈ[៤] ។

ចេះ អភិធម្ម ជាការល្អ
តែស្រវឹង ធម៌ មិនល្អទេ

---

[៤]- អភិធម្មបិដក វិភង្គ ៨១-០១-០១

# បដិច្ចសមុប្បាទ

សភាវធម៌ដែលជាហេតុជាផល អាស្រ័យគ្នាកើតឡើងតគ្នាដូចច្រវាក់ ជាប់គ្នាជារង្វង់មូល វិលទៅក្នុងវដ្តសំសារមិនមានទីបំផុត ប្រព្រឹត្តទៅតាមហេតុបច្ច័យ ប្រាសចាកសត្វបុគ្គល ដោយមិនមាននរណាជាអ្នកសាង នេះហៅថា បដិច្ចសមុប្បាទ ។

## បដិច្ចសមុប្បាទ

១-មានអង្គ ១២ គឺ អវិជ្ជា សង្ខារ វិញ្ញាណ នាមរូប សឡាយតនៈ ផស្សៈ វេទនា តណ្ហា ឧបាទាន ភព ជាតិ ជរាមរណៈ ។

២-មានអទ្ធា ៣ គឺ

1-អតីត : អវិជ្ជា សង្ខារ

2-បច្ចុប្បន្ន : វិញ្ញាណ នាមរូប សឡាយតនៈ ផស្សៈ វេទនា តណ្ហា ឧបាទាន ភព

3-អនាគត ជាតិ ជរាមរណៈ (សោក។ល។) ។

៣-មានវដ្តៈ ៣ គឺ

1-កិលេសវដ្ត : អវិជ្ជា តណ្ហា ឧបាទាន

2-កម្មវដ្ត : សង្ខារ កម្មភព

3-វិបាកវដ្ត : វិញ្ញាណ នាមរូប សឡាយតនៈ

ផស្សៈ វេទនា ។

៤-មានសន្ធិ ៣ គឺ

1-អតីត និង បច្ចុប្បន្នផល ៖ សង្ខារ វិញ្ញាណ

2-បច្ចុប្បន្នផល និង បច្ចុប្បន្នហេតុ ៖ វេទនា តណ្ហា

3-បច្ចុប្បន្នហេតុ និង អនាគតផល ៖ ភព ជាតិ ។

៥-មានសង្ខេប ៤ គឺ

1-អតីតហេតុ ៖ អវិជ្ជា សង្ខារ

2-បច្ចុប្បន្នផល ៖ វិញ្ញាណ នាមរូប សឡាយតនៈ ផស្សៈ វេទនា

3-បច្ចុប្បន្នហេតុ៖ តណ្ហា ឧបាទាន ភព

4-អនាគតផល ៖ ជាតិ ជរាមរណៈ (សោក។ល។)

៦-មានអាការៈ ២០ គឺ ៖

1-អតីតហេតុ ៥ ៖ អវិជ្ជា សង្ខារ តណ្ហា ឧបាទាន ភព

2-បច្ចុប្បន្នផល ៥៖ វិញ្ញាណ នាមរូប សឡាយតនៈ ផស្សៈ វេទនា

3-បច្ចុប្បន្នហេតុ ៥៖ អវិជ្ជា សង្ខារ តណ្ហា ឧបាទាន ភព

4-អនាគតផល ៥ ៖ វិញ្ញាណ នាមរូប សឡាយតនៈ ផស្សៈ វេទនា ។

៧-មានមូល ២ គឺ

1-អវិជ្ជា

2-តណ្ហា ។

មនុស្សយើង ព្រោះមានអវិជ្ជាសេចក្តីមិនដឹងនូវអរិយសច្ច ៤ ជាបច្ច័យ ទើបកើតមានសេចក្តីនឹកគិតក្នុងរឿងបាបក៏មាន ក្នុងរឿងបុណ្យក៏មាន ដែលហៅថា សង្ខារ សង្ខារនេះ ជាបច្ច័យឲ្យកើតវិញ្ញាណ (បដិសន្ធិវិញ្ញាណ) វិញ្ញាណជាបច្ច័យឲ្យកើតនាមរូប នាមរូបជាបច្ច័យ ឲ្យកើតសឡាយតនៈ សឡាយតនៈ ជាបច្ច័យឲ្យកើតផស្សៈ ផស្សៈជាបច្ច័យ ឲ្យកើតវេទនា វេទនាជាបច្ច័យឲ្យកើតតណ្ហា តណ្ហាជាបច្ច័យ ឲ្យកើតឧបាទាន ឧបាទានជាបច្ច័យឲ្យកើតភព ភពជាបច្ច័យ ឲ្យកើតជាតិ ជាតិជាបច្ច័យ ឲ្យកើតជរា មរណៈ សោកៈ បរិទេវៈ ទុក្ខៈ ទោមនស្សៈ ឧបាយាសៈ ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយប្រការដូច្នេះ ។

សត្វលោក តែងលិចលង់ក្នុងវដ្តសំសារ កើត ស្លាប់ ។ យ៉ាងនេះមិនមានទីបំផុត ប៉ុន្តែ ដោយសារ ព្រះសុគត សម្មាសម្ពុទ្ធបរមគ្រូរបស់យើង ព្រះអង្គរកឃើញបដិច្ចសមុប្បាទនេះ រកឃើញមូលរបស់វា គឺ អវិជ្ជា និង តណ្ហា ព្រមទាំងបដិបទាដើម្បីលះអវិជ្ជា និងតណ្ហានោះឲ្យដាច់ស្រឡះជាសមុច្ឆេទប្បហាន ទើបសត្វលោក

ឆ្លងវដ្តសំសារបានដល់ទីសុខសាន្ត ពោលគឺព្រះនិព្វាន លែងមានកងទុក្ខទាំងអស់នុំះ តទៅទៀតហើយ ។

## មតិមិនស្រប

លោក អ្នក ពុទ្ធបរិស័ទទាំងឡាយ ការអធិប្បាយបដិច្ចសមុប្បាទបែបនេះ បើយើងពិនិត្យរាប់មើល ឃើញថា មួយចប់បដិច្ចសមុប្បាទ ត្រូវមាន ៣ ជាតិ គឺ ជាតិមួយ មានអវិជ្ជា សង្ខារ រួចហើយស្លាប់ មានវិញ្ញាណទៅកើតជាតិមួយទៀត មាននាមរូប សឡាយតនៈ ផស្សៈ វេទនា តណ្ហា ឧបាទាន ភព រួចហើយស្លាប់ទៅកើតជាតិមួយទៀត មានជាតិ ជរា មរណៈ សោកៈ បរិទេវៈ ទុក្ខៈ ទោមនស្សៈ ឧបាយាសៈ ។ គ្រប់ប្រទេសទាំងអស់ ខ្មែរ ឡាវ ថៃ ភូមា លង្កា គេអធិប្បាយ បដិច្ចសមុប្បាទ តែរបៀបនេះ ដោយសំអាងគោលតាមគម្ពីរវិសុទ្ធិមគ្គ ។ ប៉ុន្តែ មានអ្នកប្រាជ្ញធំ ៗ ជាតិថៃ ២ អង្គ ជំនាន់មុនគឺ សម្តេចក្រុមវជីរញ្ញាណ វត្តបវរនិវេស និង ជំនាន់ក្រោយគឺ ភិក្ខុ ពុទ្ធទាសៈ វត្តសួនមោក្ខ លោកមិនយល់ស្របតាម សេចក្តីអធិប្បាយ បដិច្ចសមុប្បាទ បែប ៣ ជាតិដូច្នេះឡើយ។ ភិក្ខុ ពុទ្ធទាសៈ យល់ថា :

១-មិនត្រូវតាមគម្ពីរដើម (ព្រះត្រៃបិដក) ដែលព្រះពុទ្ធបានសំដែងទុកមកទេ ។

២-ជាការជួយគាំទ្រ អត្តា និង សស្សតទិដ្ឋិ ឲ្យលេចធ្លោឡើង ។

៣-មិនសមនឹងពាក្យថា ស្វាក្ខាតោ សន្ទិដ្ឋិកោ អកាលិកោ... ។

៤-ពិបាកបដិបត្តិ អវិជ្ជាកើតម្តង ត្រូវប្រើពេលអស់៣ជាតិទើបកើតទុក្ខ រលត់អវិជ្ជាម្តង ត្រូវស៊ីពេលអស់ ៣ ជាតិ ទើបទុក្ខរលត់ ។ បើរលត់អវិជ្ជា ត្រូវរលត់សង្ខារ រលត់សង្ខារគឺត្រូវស្លាប់ ទៅកើតក្នុងពោះម្តាយដូច្នោះមែន ម៉េចក៏ព្រះពុទ្ធរំលត់អវិជ្ជា ក្បែរគល់ពោធិព្រឹក្សហើយ មិនឃើញព្រះអង្គស្លាប់ព្រះអង្គគង់ព្រះជន្មនៅសម្តែងធម៌តមក រហូតអស់៤៥ ឆ្នាំទៀត ។

៥-បដិច្ចសមុប្បាទ កើតមួយចប់ ស៊ីពេលតែមួយភ្លែតទេក្នុង ១ ថ្ងៃ ។ បដិច្ចសមុប្បាទ កើតរាប់រយរាប់ពាន់ដង មិនមែនកើតក្នុងពោះម្តាយទេ គឺកើតគំនិតថា អញ របស់អញ ។ ក្នុងពេលឃើញរូប ឮសំឡេង... បើប្រកបដោយអវិជ្ជា នឹងកើតគំនិតថា អញអ្នកឃើញ អញអ្នកឮ... អញអ្នកទទួលសេចក្តីសុខ អញអ្នកទទួលសេចក្តីទុក្ខ ម្ល៉ោះហើយកងទុក្ខទាំងមូល រមែងកើតឡើង ។ ក្នុងពេលឃើញរូប ឮសំឡេង... បើមិនប្រកបដោយអវិជ្ជា នឹងមិនកើតគំនិត អញអ្នកឃើញ អញអ្នកឮ... អញអ្នកទទួលសេចក្តីសុខ អញអ្នកទទួលសេចក្តីទុក្ខ ដូច្នេះទេ ម្ល៉ោះហើយ

កងទុក្ខទាំងមូល នឹងរលត់អស់ ។ អវិជ្ជាជាបច្ច័យ ឲ្យកើតសង្ខារ សង្ខារជាបច្ច័យឲ្យកើតវិញ្ញាណ វិញ្ញាណជាបច្ច័យ ឲ្យកើតនាមរូប គឺកើតអញ... កើតអ្នកទទួលសុខ ទុក្ខ ក្នុងបច្ចុប្បន្ននេះឯង មិនមែនសំដៅយក ៣ ជាតិនោះទេ ។ ។ល។

## គំនិត ៣ ជាតិ កើតមកពីណា

ភិក្ខុ ពុទ្ធទាសៈ យល់ថា -

១-មកពីមិនយល់ពាក្យថាកើត ។ កើតមាន ២ យ៉ាង គឺ

1-កើតចេញពីពោះម្ដាយ

2-កើតជាគំនិតថា អញ របស់ អញ ។

២-មកពីពួកព្រាហ្មណ៍ ចូលមកបួសបួមច្រើន ក្នុងពុទ្ធសាសនា សម័យព្រះបាទអសោកមហារាជ ទើបមានគំនិតព្រាហ្មណ៍ ចូលមកលាយឡំក្នុងពុទ្ធសាសនា ។

៣-ព្រះពុទ្ធឃោសា លោកជាព្រាហ្មណ៍មកពីមុនផង លោកសរសេរតាមគេអធិប្បាយទុកមកពីមុនផង ទើបមានសេចក្ដីអធិប្បាយដូច្នេះ នៅក្នុងគម្ពីរវិសុទ្ធិមគ្គ ។ ។ល។

# មតិរបស់ភិក្ខុ ងិន ភេន

៣*៨

ខ្ញុំ ង.ភ. មិនមែនជាចៅក្រម ឬ អ្នកកាត់សេចក្ដីថា អ្នកនោះខុស អ្នកនេះត្រូវ ដូច្នេះទេ ។ ខ្ញុំ មិនបបួលឲ្យលុបគម្ពីរចោល ប៉ុន្តែ មិនចូលចិត្តឲ្យនាំគ្នាជឿផ្ដេចផ្ដេកដែរ ។ អធិប្បាយបែបរយៈវែងអន្ទោលទៅក្នុងវដ្តសំសារ តាមព្រះពុទ្ធឃោសា ក៏សមម្យ៉ាង ប៉ុន្តែ អធិប្បាយបែបខ្លី ទាន់សម័យ ទាន់ចិត្ត តាមភិក្ខុពុទ្ធទាសៈ ក៏ល្អម្យ៉ាងដែរ ។ ហេតុនេះ ស្រេចនៅលើអ្នកប្រើបញ្ញាពិចារណាចុះ ។

ខ្ញុំ សង្កេតឃើញ ពុទ្ធបរិស័ទខ្មែរ មួយចំនួន មានគំនិតខ្លី គិតអ្វីមិនដល់ប្រយោជន៍ មួយចំនួនទៀត មានគំនិតវែងជ្រុលហួសប្រយោជន៍ ទុកប្រយោជន៍ ឲ្យធ្លាក់ទៅលើដៃបរទេសអស់ ។ ខ្ញុំ មានបំណងឲ្យពុទ្ធបរិស័ទខ្មែរ ប្រើបញ្ញាឲ្យច្រើន គិតឲ្យទូលាយ គិតឲ្យវែងឆ្ងាយ គិតឲ្យម៉ត់ចត់ គិតឲ្យដល់ប្រយោជន៍ល្មម កុំឲ្យវាធ្លាក់ទៅលើបរទេស ឲ្យធ្លាក់មកលើខ្មែរយើងវិញ ។

គិត ! គិត ! គិត ! គិតហើយ គិតទៀត ។ ។ ។ សក់មួយច្រៀកជាប្រាំពីរ តូចប៉ុនសក់ហើយ នៅច្រៀកទៀត ច្រៀក។។។ ធម៌ទាំងឡាយ មានចិត្តដល់មុន... លោកឬពិភពលោក មានចិត្តជាអ្នកដឹកនាំ អ្វីៗកើតពីគំនិត គំនិតខ្ញុំកើត កំណើតខ្ញុំមាន... ។

គិត គិត គិត កុំខ្ជិលគិត ត្រូវឧស្សាហ៍គិត

កុំឆាប់ជឿគេ កុំចាញ់បោកគេ

❋❋❋

អ្វីៗកើតមកពីគំនិត
ខ្មែរនាំគ្នាគិតប្រឌិតថ្មែ
ធ្វើកើតល្អឆើតមានតម្លៃ
ហ្នឹងហើយស្នាដៃពូជអង្គរ ។

# កាលាមសូត្រ

ព្រះមានព្រះភាគ និមន្តទៅកាន់ កេសបុត្តនិគម របស់ពួកកាលាមៈ... ។ ពួកកាលាមៈ ចូលទៅគាល់ ក្រាបទូលថា – បពិត្រព្រះអង្គដ៏ចំរើន សមណព្រាហ្មណ៍មួយពួក ចូលមកកាន់កេសបុត្តនិគម សំដែង លើកតម្កើងនូវវាទៈ (លទ្ធិ) របស់ខ្លួន ហើយបៀតបៀន មើលងាយ បន្តុះបង្អាប់ ធ្វើមិនឲ្យគួរជឿនូវវាទៈរបស់ពួកដទៃទេ ។ សមណព្រាហ្មណ៍មួយពួកទៀត មកកាន់កេសបុត្តនិគម សំដែង លើកតម្កើងនូវវាទៈរបស់ខ្លួន ហើយ បៀតបៀន មើលងាយ បន្តុះបង្អាប់ ធ្វើមិនឲ្យគួរជឿនូវវាទៈរបស់ពួកដទៃដែរ។ បពិត្រព្រះអង្គដ៏ចំរើន ពួកយើងខ្ញុំ មានសេចក្តីសង្ស័យមិនដឹងថា សមណព្រាហ្មណ៍ពួកណានិយាយពិត សមណព្រាហ្មណ៍ពួកណានិយាយកុហក ។ ព្រះមានព្រះភាគត្រាស់ថា រឿងហ្នឹងគួរតែសង្ស័យមែន ។ ម្នាលកាលាមៈ - អ្នកកុំជឿ

១-មា **អនុស្សវេន** កុំជឿដោយគ្រាន់តែឮតាមគ្នា (ពាក្យ- ចចាមអារាម) ។

២-មា **បរម្បរាយ** កុំជឿតាមបរម្បរា ឮតៗគ្នា កាន់តៗគ្នា ជាទម្លាប់ ។

៣-មា **ឥតិកិរាយ** កុំជឿដោយបានឮមកថាដូច្នេះ

រឿងព្រេង ។

៤-មា **បិដកសម្បទានេន** កុំជឿតាមតម្រា កុំជឿតាមបិដក ។

៥-មា **តក្កហេតុ** កុំជឿតាមហេតុដែលត្រិះរិះ កុំជឿតាមតក្កវិជ្ជា ។

៦-មា **នយហេតុ** កុំជឿតាមការកាត់ជំរួយផ្សែផ្សំ ការសន្និដ្ឋាន ។

៧-មា **អាការបរិវិតក្កេន** កុំជឿតាមការត្រិះរិះទូវ-អាការៈ (អ្វីដែលបញ្ចេញមកខាងក្រៅ) ។

៨-មា **ទិដ្ឋិនិជ្ឈានក្ខន្តិយា** កុំជឿដោយយល់ឃើញថាត្រូវគ្នានឹងទិដ្ឋិ (ទ្រឹស្តី) ដែលបានពិនិត្យហើយ ។

៩-មា **ភព្វរូបតាយ** កុំជឿដោយយល់ឃើញថា មានសភាពគួរឲ្យជឿបាន ។

១០-មា **សមណោ នោ គរូ** កុំជឿដោយគិតថា សមណៈនេះ ជាគ្រូរបស់យើង ។

ម្នាលកាលាមៈ កាលបើអ្នកទាំងឡាយ ដឹងដោយខ្លួនឯងថា ធម៌ទាំងឡាយនេះជាអកុសល ប្រកបដោយទោស អ្នកប្រាជ្ញតិះដៀល បុគ្គលបដិបត្តិតាមហើយ ប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ដើម្បីទុក្ខ អ្នកទាំងឡាយ ត្រូវលះធម៌នោះចេញ ។

ម្នាលកាលាមៈ អ្នកសំគាល់សេចក្ដីនេះថាដូចម្ដេច លោភៈ ទោសៈ មោហៈ កើតឡើងក្នុងសន្ដានចិត្ត តើដើម្បីជាប្រយោជន៍ ឬ មិនជាប្រយោជន៍ មិនជាប្រយោជន៍ទេ ព្រះអង្គ ។ ម្នាលកាលាមៈ បុគ្គលអ្នកប្រកបដោយ លោភៈ ទោសៈ មោហៈ តើប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្ដីទុក្ខ អស់កាលជាអង្វែងដល់បុគ្គលនោះដែរឬទេ យ៉ាងហ្នឹងមែនហើយ ព្រះអង្គ ។ ម្នាលកាលាមៈ អ្នកសំគាល់សេចក្ដីនេះថាដូចម្ដេច អលោភៈ អទោសៈ អមោហៈ កើតឡើងក្នុងសន្ដានចិត្ត តើដើម្បីជាប្រយោជន៍ ឬ មិនជាប្រយោជន៍ ជាប្រយោជន៍ ព្រះអង្គ ។ ម្នាលកាលាមៈ បុគ្គលអ្នកប្រកបដោយ អលោភៈ អទោសៈ អមោហៈ តើប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខ អស់កាលជាអង្វែងដល់បុគ្គលនោះដែរឬទេ យ៉ាងហ្នឹងមែនហើយ ព្រះអង្គ ។ល។

បពិត្រព្រះអង្គដ៏ចំរើន ច្បាស់ណាស់ ពិរោះណាស់... យើងខ្ញុំព្រះអង្គ សូមដល់នូវព្រះមានព្រះភាគផង ព្រះធម៌ផង ព្រះសង្ឃផង ជាទីពឹង... ស្មើដោយជីវិតតាំងពីថ្ងៃនេះជាដើមតទៅ [២]៕

---

[២]- សុត្តន្តបិដក អង្គុត្តរនិកាយ តិកនិបាត ៤១-៦៧-២១៦

## កំណត់ចំណាំ

១-ព្រះពុទ្ធ មិនមែនបដិសេធរឿងទាំងអស់នោះទេ ប៉ុន្តែព្រះអង្គ បើកឱកាសឲ្យគេមានសេរីភាព ឲ្យគេគិត ឲ្យគេប្រើបញ្ញា បើគេឃើញថា ត្រឹមត្រូវ មានហេតុផល មានប្រយោជន៍ ជឿទៅ បដិបត្តិទៅ ។ ព្រះពុទ្ធ មិនដែលបង្ខំ ឬ បង្គាប់ឲ្យនរណាជឿទេ ។

២-ការប្រកាសដូច្នេះ ទុកជាសេចក្តីក្លាហានរបស់ព្រះពុទ្ធរបស់ពុទ្ធសាសនា ។

៣-ក្រៅពី ពុទ្ធសាសនា មិនមានសាសនា ណា ឬ សាស្តាណា មានសេចក្តីក្លាហាន ហ៊ានប្រកាសដូច្នេះទេ ។

៤-យើងជាសិស្សរបស់ព្រះពុទ្ធ កុំជឿផ្តេច ត្រូវប្រើបញ្ញាពិចារណាឲ្យម៉ត់ចត់ ៕

សទ្ធាឥតបញ្ញា មិនរាប់ថាសទ្ធាទេ
ហេតុនេះទើបបានគេ ដាក់ឈ្មោះថាសទ្ធាខ្វាក់ ។

# មហាបទេស ៤

## សំរាប់រៀនទូទៅ

៚

គ្រានោះ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងភណ្ឌគ្រាម តាមសមគួរដល់ពុទ្ធអធ្យាស្រ័យហើយ ទ្រង់ហៅព្រះអានន្ទមានអាយុមកថា ម្នាលអានន្ទ មកយើងទៅកាន់ ហត្ថិគ្រាម អម្ពគ្រាម ជម្ពុគ្រាម និង ភោគនគរ ។ ព្រះអានន្ទ មានអាយុ ទទួលព្រះ-បន្ទូលព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ លំដាប់នោះ ព្រះមានព្រះភាគ ព្រមដោយភិក្ខុសង្ឃដ៏ច្រើន ទ្រង់ពុទ្ធដំណើរទៅដល់ភោគនគរ ។ បានឮថា ព្រះមានព្រះភាគ ទ្រង់គង់នៅអានន្ទចេតិយ ជិតភោគនគរនោះ ។ ក្នុងទីនោះឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ តថាគត នឹងសម្តែង មហាបទេស ៤ នេះ អ្នកទាំងឡាយចូរស្តាប់ ចូរធ្វើទុកក្នុងចិត្តដោយប្រពៃចុះ តថាគត នឹងសម្តែង ។ ភិក្ខុទាំងឡាយ ទទួលព្រះបន្ទូលព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា –

១-ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ គប្បីពោលយ៉ាងនេះថា ម្នាលអាវុសោ ពាក្យនោះ ខ្ញុំបានស្តាប់ បានទទួលមកចំពោះព្រះភក្ត្រព្រះមានព្រះភាគថា នេះជាធម៌ នេះជាវិន័យ

នេះជាពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា ដូច្នេះ អ្នកទាំងឡាយ កុំគប្បីត្រេកអរ កុំគប្បីជំទាស់ពាក្យរបស់ភិក្ខុនោះ រួចហើយ គប្បីរៀនបទ និង ព្យញ្ជនៈទាំងនោះឲ្យល្អ ហើយផ្ទៀងផ្ទាត់ក្នុងព្រះសូត្រ ប្រៀបធៀបក្នុងព្រះវិន័យ បើផ្ទៀងផ្ទាត់ក្នុងព្រះសូត្រ ប្រៀបធៀបក្នុងព្រះវិន័យហើយ ចូលក្នុងព្រះសូត្រមិនបាន ចូលក្នុងព្រះវិន័យក៏មិនបាន អ្នកគប្បីសម្រេចក្នុងពាក្យនេះថា នេះ មិនមែនជាព្រះពុទ្ធដីការបស់ព្រះមានព្រះភាគពិតប្រាកដ ភិក្ខុនេះ ចាំមកខុសហើយដូច្នេះ អ្នកទាំងឡាយ គប្បីបោះបោលពាក្យនុ៎ះចុះ ។ បើផ្ទៀងផ្ទាត់ក្នុងព្រះសូត្រ ប្រៀបធៀបក្នុងព្រះវិន័យ ចូលក្នុងព្រះ-សូត្របាន ចូលក្នុងព្រះវិន័យក៏បាន អ្នកទាំងឡាយគប្បីសម្រេចក្នុងពាក្យនេះថា នេះជា ព្រះពុទ្ធដីកា របស់ព្រះមានព្រះភាគពិតប្រាកដមែន ភិក្ខុនេះចាំមកត្រឹមត្រូវហើយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីចាំទុកនូវមហាបទេសទី១ នេះចុះ ។

២-ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ គប្បីពោលយ៉ាងនេះថា ព្រះសង្ឃក្នុងអាវាសឯណោះ មានទាំងភិក្ខុជាថេរៈ មានទាំងភិក្ខុជាប្រធាន (បាមោក្ខ) ខ្ញុំបានស្តាប់ បានទទួលមកចំពោះមុខព្រះសង្ឃនោះថា នេះជាធម៌ នេះជាវិន័យ នេះជាពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា អ្នកទាំងឡាយ កុំគប្បីត្រេកអរ កុំគប្បីជំទាស់ពាក្យរបស់ភិក្ខុនោះ ។ រួចហើយ... ។ល។

៣-ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនា នេះ គប្បីពោល យ៉ាងនេះថា ភិក្ខុជាថេរៈច្រើនអង្គ ក្នុងអាវាសឯណោះ សុទ្ធតែជាពហុស្សូត ចេះចាំក្នុងគម្ពីរនិកាយ ទ្រទ្រង់ធម៌ ទ្រទ្រង់វិន័យ ទ្រទ្រង់មាតិកា ខ្ញុំបានស្ដាប់ បានទទួលមកចំពោះមុខព្រះថេរៈទាំងនោះថា នេះ ជាធម៌ នេះ ជាវិន័យ នេះ ជាពាក្យប្រៀនប្រដៅរបស់ព្រះសាស្ដា អ្នកទាំងឡាយ កុំគប្បីត្រេកអរ កុំគប្បីជំទាស់ពាក្យរបស់ភិក្ខុនោះ ។ រួចហើយ ។ល។

៤-ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ គប្បីពោលយ៉ាងនេះថា ភិក្ខុជាថេរៈក្នុងអាវាសឯណោះ ជាពហុស្សូត ចេះចាំក្នុងគម្ពីរនិកាយ ទ្រទ្រង់ធម៌ ទ្រទ្រង់វិន័យ ទ្រទ្រង់មាតិកា ខ្ញុំបានស្ដាប់ បានទទួលមកចំពោះមុខព្រះថេរៈអង្គនោះថា នេះជាធម៌ នេះជាវិន័យ នេះជាពាក្យប្រៀនប្រដៅរបស់ព្រះសាស្ដា អ្នកទាំងឡាយ កុំគប្បីត្រេកអរ កុំគប្បីជំទាស់ពាក្យរបស់ភិក្ខុនោះ ។ រួចហើយ គប្បីរៀនបទ និង ព្យញ្ជនៈទាំងនោះឲ្យល្អ ហើយផ្ទៀងផ្ទាត់ក្នុងព្រះសូត្រ ប្រៀបធៀបក្នុងព្រះវិន័យ បើផ្ទៀងផ្ទាត់ក្នុងព្រះសូត្រ ប្រៀបធៀបក្នុងព្រះវិន័យ ចូលក្នុងព្រះសូត្រមិនបាន ចូលក្នុងព្រះវិន័យក៏មិនបាន អ្នកគប្បីសម្រេចក្នុងពាក្យនេះថា នេះ មិនមែនជាព្រះពុទ្ធដីការបស់ព្រះមានព្រះភាគពិតប្រាកដ ភិក្ខុនេះចាំមកខុសហើយដូច្នេះ អ្នកទាំងឡាយ គប្បីបោះបោលពាក្យនុ៎ះចុះ ។

បើផ្ទៀងផ្ទាត់ក្នុងព្រះសូត្រ ប្រៀបធៀបក្នុងព្រះវិន័យ ចូលក្នុងព្រះសូត្របាន ចូលក្នុងព្រះវិន័យក៏បាន អ្នកគប្បីសម្រេចក្នុងពាក្យនេះថា នេះជាធម៌ នេះជាវិន័យ នេះជាព្រះពុទ្ធដីការបស់ព្រះមានព្រះភាគពិតមែន ភិក្ខុនេះ ចាំមកត្រឹមត្រូវហើយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីចាំទុកនូវមហាបទេស ទី ៤ នេះចុះ ។ ម្នាលភិក្ខុទាំងឡាយ គប្បីចាំទុកនូវមហាបទេសទាំង ៤ នេះឯង[៣]។

។ល។

## កំណត់ចំណាំ

១-ការអះអាងយកបុគ្គលវិសេស គឺព្រះពុទ្ធក្តី

២-ការអះអាងយកសង្ឃទាំងមូលគឺ គណៈសង្ឃក្តី

៣-ការអះអាងយកក្រុមបុគ្គលគឺ ព្រះថេរៈច្រើនអង្គក្តី

៤-ការអះអាងយកបុគ្គលគឺ ព្រះថេរៈ ១ អង្គក្តី

ការអះអាងទាំងអស់នេះ ព្រះពុទ្ធ មិនទាន់ឲ្យយកជាការត្រឹមត្រូវទេ បានជាព្រះអង្គមិនឲ្យត្រេកអរ ប៉ុន្តែ ព្រះអង្គ ក៏មិនសព្វព្រះទ័យឲ្យមានជំទាស់ដែរ តែឲ្យផ្ទៀងផ្ទាត់ក្នុងព្រះសូត្រ ប្រៀបធៀបក្នុងព្រះវិន័យ បើចូលគ្នាបានសព្វគ្រប់ហើយ យកជាការចុះ ។

---

[៣]- សុត្តន្តបិដក ទីឃនិកាយ មហាបរិនិព្វានសូត្រ ១៦-១១២-២៦១

សង្កេត :

ព្រះពុទ្ធ បានប្រាប់ឲ្យផ្ទៀងផ្ទាត់ក្នុងព្រះសូត្រ ឲ្យប្រៀបធៀបក្នុងព្រះវិន័យ មិនឃើញមាន អភិធម្ម ព្រោះអ្វី ? ព្រោះក្នុងសម័យព្រះពុទ្ធ មិនមានគម្ពីរ អភិធម្ម ទេ ។ មានពាក្យថា អភិធម្ម ពាក្យថា បិដក ដែរ ប៉ុន្តែ មានន័យផ្សេង មិនមែនសំដៅយក គម្ពីរ អភិធម្មបិដក ដូចពួកយើងសព្វថ្ងៃយល់នោះទេ ។ សម័យនោះប្រើពាក្យថា ធម៌ និង វិន័យ ឧទាហរណ៍ ព្រះពុទ្ធត្រាស់ថា ម្នាលអានន្ទ ធម៌ណាក្តី វិន័យណាក្តី ដែលតថាគតសម្តែងហើយ បញ្ញត្តហើយ ដល់អ្នកទាំងឡាយ លុះអំណើះតទៅ អំពីតថាគតទៅ ធម៌ និង វិន័យនោះ ជាគ្រូរបស់អ្នកទាំងឡាយ [៤]។

សូម្បីក្នុងពេលធ្វើ បឋមសង្គាយនា ក៏មិនមានចែកជា វិន័យបិដក សុត្តន្តបិដក អភិធម្មបិដក ដែរ ។ គេគ្មានបាននិយាយថា ព្រះមហាកស្សប សួរ វិន័យបិដក នឹងព្រះឧបាលី សួរ សុត្តន្តបិដក និង អភិធម្មបិដក នឹងព្រះអានន្ទ ដូចលោកទេសនីគ្រែពា សម័យឥឡូវនេះទេ ។ គេប្រើត្រឹមតែពាក្យថា ព្រះមហាកស្សប សួរវិន័យ នឹងព្រះឧបាលី សួរធម៌ នឹងព្រះអានន្ទ

---

[៤]- សុត្តន្តបិដក ទីឃនិកាយ មហាបរិនិព្វានសូត្រ ១៦-១៤១-៣២០

ប៉ុណ្ណឹង [៥]។ ដូច្នេះ អ្នកសិក្សា កុំភ្លេចបើកភ្នែក ។

ពុទ្ធសករាជកន្លងទៅបាន ៤៣៣ ឆ្នាំ មានការប្រជុំនៅប្រទេសសិរីលង្កា គេបានកត់ត្រា ចែកពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ជាព្រះត្រៃបិដក គឺ វិនយបិដក សុត្តន្តបិដក អភិធម្មបិដក តាំងពីនោះមក ។

## មហាបទេស ៤

## សំរាប់រៀង ព្រះវិន័យ

សម័យនោះឯង ភិក្ខុទាំងឡាយ កើតសេចក្តីរង្កៀសក្នុងកន្លែងជាអន្លើៗថា របស់អ្វីហ្ន៎ ព្រះមានព្រះភាគ ទ្រង់អនុញ្ញាត របស់អ្វីហ្ន៎ មិនទ្រង់អនុញ្ញាត ទើបក្រាបទូលសេចក្តីនោះចំពោះព្រះមានព្រះភាគ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់មហា-បទេស (ខអាងធំ) ដូចតទៅនេះ –

១-ម្នាលភិក្ខុទាំងឡាយ របស់ណាដែលតថាគត មិនបានហាមទុកថា របស់នេះមិនគួរ (អកប្បិយៈ) បើរបស់នោះអនុលោមចូលគ្នានឹងរបស់មិនគួរ ទំនាស់នឹងរបស់គួរ (កប្បិយៈ) របស់នោះ

---

[៥]- វិនយបិដក ចុល្លវគ្គ បញ្ចសតិកក្ខន្ធកៈ ១១-២៧៨-៣៥៦

មិនគួរដល់អ្នកទាំងឡាយទេ ។

២-ម្នាលភិក្ខុទាំងឡាយ របស់ណាដែលតថាគត មិនបាន ហាមទុកថា របស់នេះមិនគួរ បើរបស់នោះអនុលោមចូលគ្នានឹង របស់គួរ ទំនាស់នឹងរបស់មិនគួរ របស់នោះគួរដល់អ្នកទាំង ឡាយហើយ ។

៣-ម្នាលភិក្ខុទាំងឡាយ របស់ណាដែលតថាគត មិនបាន អនុញ្ញាតទុកថា របស់នេះគួរ បើរបស់នោះអនុលោមចូលគ្នានឹង របស់មិនគួរ ទំនាស់នឹងរបស់គួរ របស់នោះមិនគួរដល់អ្នកទាំង ឡាយទេ ។

៤-ម្នាលភិក្ខុទាំងឡាយ របស់ណាដែលតថាគត មិនបាន អនុញ្ញាតទុកថា របស់នេះគួរ បើរបស់នោះអនុលោមចូលគ្នានឹង របស់គួរ ទំនាស់នឹងរបស់មិនគួរ របស់នោះគួរដល់អ្នកទាំងឡាយ ហើយ [៦]៕

## កំណត់ចំណាំ

ព្រះពុទ្ធបរមគ្រូរបស់យើង ព្រះអង្គមានព្រះបញ្ញាញាណ ដ៏សែនវែងឆ្ងាយ រកទីបំផុតគ្មាន ទើបទ្រង់សម្តែងមហាបទេសនេះ ទុក ។ រឿងនេះ មានប្រយោជន៍ច្រើនទូលំទូលាយណាស់ ។

---

[៦]- វិនយបិដក មហាវគ្គ ភេសជ្ជខន្ធកៈ ៧-១៤០-៣៧៧

ឧទាហរណ៏ :

១-ព្រះអង្គ មិនបានហាមទុកថា អាភៀនជារបស់មិនគួរ ប៉ុន្តែ វាអនុលោមចូលគ្នានឹងរបស់មិនគួរគឺ សុរាមេរ័យ ដូច្នេះ វាជារបស់មិនគួរទេ ។

២-ព្រះអង្គ មិនបានអនុញ្ញាតទុកថា សម ស្លាបព្រា ជារបស់គួរ ប៉ុន្តែ វាអនុលោមចូលគ្នានឹងរបស់គួរគឺ ភាជនៈ ដូច្នេះ វាជារបស់គួរហើយ ។

រឿងគួរប្រយ័ត្ន សេចក្តីសម្រេចថា អ្វីគួរ អ្វីមិនគួរ មិនគប្បីយកបុគ្គលជាប្រមាណទេ ត្រូវតែយកគណៈសង្ឃជាប្រមាណ ទើបអាចរក្សាបាននូវសាមគ្គីភាព និង ភាពថ្លៃថ្នូរយូរអង្វែង នៃព្រះសាសនា ៕

## លក្ខណៈកាត់សេចក្តីធម៌វិន័យ ៨ ប្រការ

គ្រានោះ ព្រះនាងបជាបតីគោតមី បានចូលទៅគាល់ ព្រះមានព្រះភាគ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះអង្គសម្តែងធម៌ដោយសង្ខេប ដល់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គស្តាប់ធម៌ហើយនឹងចេញទៅរកទីកន្លែងស្ងប់ស្ងាត់បដិបត្តិធម៌ ។

ព្រះមានព្រះភាគ ត្រាស់ថា ម្នាលព្រះនាងគោតមី ព្រះនាងគប្បីដឹងនូវធម៌ទាំងឡាយណាដែល :

១-**សរាគាយ សំវត្តន្តិ នោ វិរាគាយ** ប្រព្រឹត្តទៅដើម្បីការប្រកបដោយតម្រេក មិនប្រព្រឹត្តទៅ ដើម្បីការប្រាសចាកតម្រេក ។

២-**សញ្ញោគាយ សំវត្តន្តិ នោ វិសញ្ញោគាយ** ប្រព្រឹត្តទៅដើម្បីការប្រកបក្នុងវដ្តៈ មិនប្រព្រឹត្តទៅដើម្បីការប្រាសចាកការប្រកបក្នុងវដ្តៈ ។

៣-**អាចយាយ សំវត្តន្តិ នោ អបចយាយ** ប្រព្រឹត្តទៅដើម្បីការសន្សំកិលេសវដ្តៈ មិនប្រព្រឹត្តទៅដើម្បីការប្រាសចាកការសន្សំកិលេសវដ្តៈ ។

៤-**មហិច្ឆតាយ សំវត្តន្តិ នោ អប្បិច្ឆតាយ** ប្រព្រឹត្តទៅដើម្បីសេចក្តីប្រាថ្នាច្រើន មិនប្រព្រឹត្តទៅដើម្បីសេចក្តីប្រាថ្នាតិច។

៥-**អសន្តុដ្ឋិយា សំវត្តន្តិ នោ សន្តុដ្ឋិយា** ប្រព្រឹត្តទៅដើម្បីសេចក្តីមិនសន្តោស មិនប្រព្រឹត្តទៅដើម្បីសេចក្តីសន្តោស ។

៦-**សង្គណិកាយ សំវត្តន្តិ នោ បវិវេកាយ** ប្រព្រឹត្តទៅដើម្បីការច្រឡូកច្រឡំដោយពួក មិនប្រព្រឹត្តទៅដើម្បីការស្ងប់ស្ងាត់ ។

៧-**កោសជ្ជាយ សំវត្តន្តិ នោ វីរិយារម្ភាយ** ប្រព្រឹត្តទៅដើម្បីសេចក្តីខ្ជិលច្រអូស មិនប្រព្រឹត្តទៅដើម្បីការប្រារព្ធសេចក្តីព្យាយាម ។

**៨-ឱឡារិកោ សំវត្តន្តិ នោ សុភរតាយ** ប្រព្រឹត្តទៅដើម្បីឲ្យគេចិញ្ចឹមបានដោយកម្រ មិនប្រព្រឹត្តទៅដើម្បីឲ្យគេចិញ្ចឹមបានដោយងាយ ។

ម្នាលព្រះនាងគោតមី ព្រះនាងគប្បីចាំទុកដោយចំណែកមួយថា នេះ មិនមែនជាធម៌ នេះ មិនមែនជាវិន័យ នេះ មិនមែនជាពាក្យប្រៀនប្រដៅរបស់ព្រះសាស្តាទេ ។

ម្នាលព្រះនាងគោតមី ព្រះនាងគប្បីដឹងនូវធម៌ទាំងឡាយណាដែល:

**១-វិរាគាយ សំវត្តន្តិ នោ សរាគាយ** ប្រព្រឹទៅដើម្បីការប្រាសចាកតម្រេក មិនប្រព្រឹត្តទៅដើម្បីការប្រកបដោយតម្រេក ។

**២-វិសញ្ញោគាយ សំវត្តន្តិ នោ សញ្ញោគាយ** ប្រព្រឹត្តទៅដើម្បីការប្រាសចាកការប្រកបក្នុងវដ្តៈ មិនប្រព្រឹត្តទៅដើម្បីការប្រកបក្នុងវដ្តៈ ។

**៣-អបចយាយ សំវត្តន្តិ នោ អាចយាយ** ប្រព្រឹត្តទៅដើម្បីការមិនសន្សំកិលេសវដ្តៈ មិនប្រព្រឹត្តទៅដើម្បីការសន្សំកិលេសវដ្តៈ ។

**៤-អប្បិច្ឆតាយ សំវត្តន្តិ នោ មហិច្ឆតាយ** ប្រព្រឹត្តទៅដើម្បីសេចក្ដីប្រាថ្នាតិច មិនប្រព្រឹត្តទៅដើម្បីសេចក្ដីប្រាថ្នាច្រើន។

៥-**សន្តុដ្ឋិយា សំវត្តន្តិ នោ អសន្តុដ្ឋិយា** ប្រព្រឹត្តទៅដើម្បីសេចក្ដីសន្ដោស មិនប្រព្រឹត្តទៅដើម្បីសេចក្ដីមិនសន្ដោស ។

៦-**បវិវេកាយ សំវត្តន្តិ នោ សង្គណិកាយ** ប្រព្រឹត្តទៅដើម្បីការស្ងប់ស្ងាត់ចាកពួក មិនប្រព្រឹត្តទៅដើម្បីការច្រឡូកច្រឡំដោយពួក ។

៧-**វិរិយារម្ភាយ សំវត្តន្តិ នោ កោសជ្ជាយ** ប្រព្រឹត្តទៅដើម្បីការប្រារព្ធសេចក្ដីព្យាយាម មិនប្រព្រឹត្តទៅដើម្បីសេចក្ដីខ្ជិលច្រអូស ។

៨-**សុភរតាយ សំវត្តន្តិ នោ ទុព្ភរតាយ** ប្រព្រឹត្តទៅដើម្បីឲ្យគេចិញ្ចឹមបានដោយងាយ មិនប្រព្រឹត្តទៅដើម្បីឲ្យគេចិញ្ចឹមបានដោយកម្រ ។

ម្នាលព្រះនាងគោតមី ព្រះនាងគប្បីចាំទុកដោយចំណែកមួយថា នេះ ជាធម៌ នេះ ជាវិន័យ នេះ ជាពាក្យប្រៀនប្រដៅរបស់ព្រះសាស្ដាហើយ [៧]៕

---

[៧]- វិនយបិដក ចុល្លវគ្គ ភិក្ខុនីខន្ធកៈ ១១-១៨៦-២៧៦

<u>មតិរបស់ខ្ញុំ</u> :

ដូចម្ដេច ហៅថា ចិញ្ចឹមងាយ ។ ចិញ្ចឹមងាយ គឺ:

១-ងាយរស់ អំបិលក៏បាន បន្លែក៏បាន ត្រីក៏បាន សាច់ក៏បាន ក្ដៅក៏បាន ត្រជាក់ក៏បាន ។ល។ និយាយខ្លី គឺ ប្រើប្រាស់បច្ច័យ៤តាមមានតាមបាន ។

២-ធ្វើឲ្យគេជ្រះថ្លា ខំបដិបត្តិធម៌ លះសេចក្ដីលោភលន់ លះសេចក្ដីក្រេវក្រោធ ។ល។ មានចិត្តមេត្តា ករុណា ជាដើម។

៣-ជួយដោះស្រាយទុក្ខ ឬ សេចក្ដីទ័លក្ររបស់ប្រជាជន តាមមធ្យោបាយប្រកបដោយធម៌ គឺ អប់រំ អភិវឌ្ឍសង្គមជាដើម។

អ្នកបួសមានគុណសម្បត្តិប៉ុណ្ណេះជាដើម គេមិនពិបាកចិញ្ចឹមទេ ។ ដូច្នេះ អ្នកបួសកុំគិតតែប្រយោជន៍ផ្ទាល់ខ្លួន ត្រូវខំបដិបត្តិធម៌ និង ជួយគិតគូរដល់បញ្ហាទុក្ខលំបាករបស់ប្រជាជនតាមការគួរ ៕

កុំស៊ីឆ្អាញ់តែឯង ត្រូវចេះបែងចែកគេផង

# មហាសក្យមុនិគោតមសូត្រ

## បរិវិតក្ករបស់ព្រះបរមពោធិសត្វ

[២៦] ម្នាលភិក្ខុទាំងឡាយ កាលតថាគតនៅជាពោធិសត្វ មិនទាន់បានត្រាស់ដឹងនៅឡើយ ក្នុងកាលមុនអំពីការត្រាស់ដឹង មានសេចក្ដីត្រិះរិះដូច្នេះថា ឱហ្ន៎ សត្វលោកនេះ ដល់នូវសេចក្ដី លំបាកណាស់ តែងកើត ចាស់ ស្លាប់ ច្យុត និង ចាប់បដិសន្ធិ ថែមទាំងមិនដឹងច្បាស់នូវការរលាស់ចោលសេចក្ដីទុក្ខ គឺ ជរា និង មរណៈនេះទៀតផង កាលណាទៅហ្ន៎ ទើបការរលាស់ចោល សេចក្ដីទុក្ខ គឺ ជរា និង មរណៈនេះ នឹងប្រាកដឡើងបាន ។ ម្នាលភិក្ខុទាំងឡាយ តថាគតនោះ មានសេចក្ដីត្រិះរិះដូច្នេះ កាលអ្វីហ្ន៎កើតមាន ទើបជរា និង មរណៈ កើតមាន ព្រោះអ្វីជា បច្ច័យ ទើបជរា និង មរណៈ កើតមាន ។ ម្នាលភិក្ខុទាំងឡាយ តថាគតនោះ ក៏បានត្រាស់ដឹងដោយប្រាជ្ញា ព្រោះយោនិសោ-មនសិការៈ ថា កាលបើជាតិកើតមាន ទើបជរា និង មរណៈ កើត មាន ព្រោះជាតិជាបច្ច័យ ទើបជរា និង មរណៈ កើតមាន ។ ម្នាលភិក្ខុទាំងឡាយ តថាគតនោះ មានសេចក្ដីត្រិះរិះដូច្នេះថា កាលអ្វីហ្ន៎កើតមាន ទើបជាតិកើតមាន ។បេ។ ភព... ឧបាទាន តណ្ហា... វេទនា... ផស្សៈ... សឡាយតនៈ... នាមរូប...

វិញ្ញាណ... កាលអ្វីហ្ន៎កើតមាន ទើបសង្ខារទាំងឡាយកើតមាន ព្រោះអ្វីជាបច្ច័យ ទើបសង្ខារទាំងឡាយកើតមាន ។ ម្នាលភិក្ខុទាំងឡាយ តថាគតនោះ ក៏បានត្រាស់ដឹងដោយប្រាជ្ញា ព្រោះយោនិសោមនសិការៈ ថា កាលបើអវិជ្ជាកើតមាន សង្ខារទាំងឡាយក៏កើតមាន ព្រោះអវិជ្ជាជាបច្ច័យ ទើបសង្ខារទាំងឡាយកើតមាន ។ ព្រោះហេតុដូច្នេះ សង្ខារទាំងឡាយកើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណកើតមាន ព្រោះសង្ខារជាបច្ច័យ ។បេ។ ការកើតឡើងព្រមនៃកងទុក្ខទាំងអស់នុ៎ះ រមែងមានយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ តថាគតមានចក្ខុកើតហើយ មានញាណកើតហើយ មានបញ្ញាកើតហើយ មានវិជ្ជាកើតហើយ មានពន្លឺកើតហើយ ក្នុងធម៌ទាំងឡាយ ដែលមិនធ្លាប់បានស្តាប់ ក្នុងកាលមុនថា ការកើតឡើងព្រម ការកើតឡើងព្រម ដូច្នេះ ។

[២៧] ម្នាលភិក្ខុទាំងឡាយ តថាគតនោះ មានសេចក្តីត្រិះរិះដូច្នេះថា កាលអ្វីហ្ន៎មិនមាន ទើបជរា និង មរណៈមិនមាន ព្រោះការរលត់អ្វី ទើបជរា និង មរណៈរលត់ ។ ម្នាលភិក្ខុទាំងឡាយ តថាគតនោះ ក៏បានត្រាស់ដឹងដោយប្រាជ្ញា ព្រោះយោនិសោមនសិការៈថា កាលបើជាតិមិនមាន ជរា និង មរណៈក៏មិនមាន ព្រោះការរលត់ជាតិ ជរា និង មរណៈក៏រលត់ ។ ម្នាលភិក្ខុទាំងឡាយ តថាគតនោះ មានសេចក្តីត្រិះរិះដូច្នេះថា កាលអ្វីហ្ន៎

មិនមាន ទើបជាតិមិនមាន ។បេ។ ភព... ឧបាទាន... តណ្ហា... វេទនា... ផស្សៈ... សឡាយតនៈ... នាមរូប... វិញ្ញាណ កាលអ្វីហ្ន៎មិនមាន ទើបសង្ខារទាំងឡាយមិនមាន ព្រោះការរលត់អ្វី ទើបសង្ខារទាំងឡាយរលត់ ។ ព្រោះហេតុដូច្នេះ ការរលត់នៃសង្ខារទាំងឡាយ ព្រោះការរលត់នៃអវិជ្ជា ការរលត់នៃវិញ្ញាណ ព្រោះការរលត់នៃសង្ខារ ។បេ។ ការរលត់នៃកងទុក្ខទាំងអស់នុ៎ះ រមែងមានយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ តថាគតមានចក្ខុកើតហើយ មានញាណកើតហើយ មានបញ្ញាកើតហើយ មានវិជ្ជាកើតហើយ មានពន្លឺកើតហើយ ក្នុងធម៌ទាំងឡាយ ដែលមិនធ្លាប់បានស្តាប់ ក្នុងកាលមុនថា ការរលត់ ការរលត់ ដូច្នេះ[៨]។

<u>**កំណត់ចំណាំ**</u>

- នរណា រកឃើញ បដិច្ចសមុប្បាទធម៌ ?
- ព្រះពុទ្ធ ជាអ្នករកឃើញ បដិច្ចសមុប្បាទធម៌

រកឃើញតាំងពីព្រះអង្គ មិនទាន់បានត្រាស់ដឹង គ្រាន់តែមិនសូវច្បាស់ក្រឡែត ដូចពេលដែលបានត្រាស់ដឹងហើយ ។

- ព្រះពុទ្ធ ទ្រង់ត្រិះរិះ(បរិវិតក្ក)និងប្រើ យោនិសោមនសិការៈ យើងជាពុទ្ធបរិស័ទ គប្បីរៀនបដិបត្តិធម៌នេះ តាមព្រះអង្គ។

---

[៨]-សុត្តន្តបិដក សំយុត្តនិកាយ និទានវគ្គ អភិសមយសំយុត្ត ៣១-២៦-២០

## បច្ចយសុត្ត

[៦០] ព្រះមានព្រះភាគ គង់នៅទៀបក្រុងសាវត្ថី... ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងនូវបដិច្ចសមុប្បាទធម៌ផង នូវបដិច្ចសមុប្បន្នធម៌ផង ដល់អ្នកទាំងឡាយ អ្នកទាំងឡាយ ចូរប្រុងស្តាប់នូវសេចក្តីនោះ ចូរយកចិត្តទុកដាក់ដោយប្រពៃចុះ តថាគត នឹងសម្តែងប្រាប់ ។ ភិក្ខុទាំងឡាយនោះទទួលព្រះពុទ្ធដីកា ព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។

[៦១] ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ចុះបដិច្ចសមុប្បាទធម៌ តើដូចម្តេច ម្នាលភិក្ខុទាំងឡាយ ព្រោះជាតិជាបច្ច័យ ទើបមានជរា និង មរណៈ ព្រះតថាគតកើតឡើងក្តី ព្រះតថាគតមិនទាន់កើតឡើងក្តី ធាតុនោះ គឺ **ធម្មដ្ឋិតតា ធម្មនិយាមតា ឥទប្បច្ចយតា** តែងស្ថិតនៅជាធម្មតា តថាគតត្រាស់ដឹង យល់ច្បាស់នូវធាតុនោះ លុះត្រាស់ដឹង យល់ច្បាស់ហើយ ទើបប្រាប់ សំដែង បញ្ញត្ត តែងតាំង បើកបង្ហាញ ចែករំលែក ធ្វើឲ្យរាក់ ហើយប្រាប់ថែមថា អ្នកទាំងឡាយចូរមើលចុះ។ ម្នាលភិក្ខុទាំងឡាយ ព្រោះជាតិជាបច្ច័យ ទើបមានជរានិងមរណៈ ... ព្រោះភពជាបច្ច័យ ទើបមានជាតិ... ព្រោះឧបាទានជាបច្ច័យ ទើបមានភព... ព្រោះតណ្ហាជាបច្ច័យ... ទើបមានឧបាទាន... ព្រោះវេទនាជាបច្ច័យ ទើបមានតណ្ហា... ព្រោះផស្សៈ

ជាបច្ច័យ ទើបមានវេទនា... ព្រោះសឡាយតនៈជាបច្ច័យ ទើបមានផស្សៈ... ព្រោះនាមរូបជាបច្ច័យ ទើបមានសឡាយតនៈ... ព្រោះវិញ្ញាណជាបច្ច័យ ទើបមាននាមរូប... ព្រោះសង្ខារជាបច្ច័យ ទើបមានវិញ្ញាណ... ព្រោះអវិជ្ជាជាបច្ច័យ ទើបមានសង្ខារ ព្រះតថាគតកើតឡើងក្តី ព្រះតថាគតមិនទាន់កើតឡើងក្តី ធាតុនោះ គឺ **ធម្មដ្ឋិតតា ធម្មនិយាមតា ឥទប្បច្ចយតា** តែងស្ថិតនៅជាធម្មតា តថាគត ត្រាស់ដឹង យល់ច្បាស់នូវធាតុនោះ លុះត្រាស់ដឹង យល់ច្បាស់ហើយ ទើបប្រាប់ សំដែង បញ្ញត្ត តែងតាំង បើកបង្ហាញ ចែករំលែក ធ្វើឲ្យរាក់ហើយប្រាប់ថែមថា អ្នកទាំងឡាយ ចូរមើលចុះ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះអវិជ្ជាជាបច្ច័យ ទើបមានសង្ខារ ។ ម្នាលភិក្ខុទាំងឡាយ ធម្មជាតណាជារបស់ពិត ទៀងទាត់ មិនប្រែប្រួល មានសភាវៈនេះជាបច្ច័យក្នុងធម៌នោះ ម្នាលភិក្ខុទាំងឡាយ នេះ ហៅថា បដិច្ចសមុប្បាទធម៌ ដោយប្រការដូច្នេះឯង ។

[៦២] ម្នាលភិក្ខុទាំងឡាយ ចុះបដិច្ចសមុប្បន្នធម៌ទាំងឡាយតើដូចម្តេច ម្នាលភិក្ខុទាំងឡាយ ជរា និង មរណៈ មិនទៀងដែលបច្ច័យប្រជុំតាក់តែង អាស្រ័យគ្នាកើតឡើង មានការអស់ជាធម្មតា សូន្យជាធម្មតា រលើករលាកជាធម្មតា រលត់ជាធម្មតា ។ ម្នាលភិក្ខុទាំងឡាយ ជាតិ... ភព... ឧបាទាន... តណ្ហា...

វេទនា... ផស្សៈ... សឡាយតនៈ នាមរូប... វិញ្ញាណ... សង្ខារ... អវិជ្ជា មិនទៀង(អនិច្ចា) ដែលបច្ច័យប្រជុំតាក់តែង (សង្ខតា) អាស្រ័យគ្នាកើតឡើង (បដិច្ចសមុប្បន្នា) មានការអស់ជាធម្មតា (ខយធម្មា) សូន្យជាធម្មតា (វយធម្មា) រយីករយាកជាធម្មតា (វិរាគធម្មា) រលត់ជាធម្មតា (និរោធធម្មា) ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយនេះ ហៅថា បដិច្ចសមុប្បន្នធម៌ ។

[៦៣] ម្នាលភិក្ខុទាំងឡាយ កាលណា អរិយសាវក បានឃើញនូវបដិច្ចសមុប្បាទធម៌នេះផង នូវបដិច្ចសមុប្បន្នធម៌នេះផង ដោយប្រពៃ ដោយប្រាជ្ញាដ៏ឧត្តមតាមពិត អរិយសាវកនោះ នឹងស្ទុះទៅរកទីបំផុតខាងដើមថា អាត្មាអញបានកើតហើយក្នុងអតីតកាល ដែរ ឬ ហ្ន៎ អាត្មាអញមិនបានកើតក្នុងអតីតកាលទេឬហ្ន៎ អាត្មាអញបានកើតហើយក្នុងអតីតកាល ដោយប្រការដូចម្តេចហ្ន៎ អាត្មាអញកើតជាអ្វី ហើយបានកើតជាអ្វីក្នុងអតីតកាលហ្ន៎ ដូច្នេះក្តី នឹងស្ទុះទៅរកទីបំផុតខាងចុងថា អាត្មាអញនឹងកើតក្នុងអនាគតកាល ដែរឬហ្ន៎ អាត្មាអញនឹងមិនកើតក្នុងអនាគតកាលទេឬហ្ន៎ អាត្មាអញនឹងកើតក្នុងអនាគតកាលដូចម្តេចហ្ន៎ អាត្មាអញនឹងកើតក្នុងអនាគតកាល ដោយប្រការដូចម្តេចហ្ន៎ អាត្មាអញនឹងកើតជាអ្វី ហើយកើតជាអ្វីទៅក្នុងអនាគតកាលហ្ន៎ ដូច្នេះក្តី នឹងមានសេចក្តីសង្ស័យចំពោះខន្ធខាងក្នុងជារបស់ខ្លួន ក្នុងបច្ចុប្បន្នកាល

ឥឡូវនេះថា អាត្មាអញមានដែរឬទេហ្ន៎ អាត្មាអញមិនមានទេឬហ្ន៎ អាត្មាអញមានដូចម្តេចហ្ន៎ អាត្មាអញមានដោយប្រការដូចម្តេចហ្ន៎ សត្វនេះមកពីណាហ្ន៎ សត្វនេះនឹងទៅកើតក្នុងទីណាហ្ន៎ ដូច្នេះក្តី ហេតុនេះ រមែងមិនមានឡើយ ដំណើរនោះ ព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះថា អរិយសាវក បានឃើញនូវបដិច្ច-សមុប្បាទធម៌ផង នូវបដិច្ចសមុប្បន្នធម៌ផង ដោយប្រពៃ ដោយប្រាជ្ញាដ៏ឧត្តមតាមពិត[៩] ។

## កំណត់ចំណាំ :

១-បដិច្ចសមុប្បាទធម៌ក្តី បដិច្ចសមុប្បន្នធម៌ក្តី ព្រះជិនស្រីទ្រង់សម្តែងទុកសព្វគ្រប់ហើយ ។ អ្នកអាន កុំអានចប់ ចប់ គឺមិនដឹងសេចក្តីថាយ៉ាងម៉េច... ។ សំរាប់ខ្ញុំ ខ្ញុំយល់ថា បដិច្ច-សមុប្បាទធម៌ និង បដិច្ចសមុប្បន្នធម៌ ជាធម៌ជាមួយគ្នា គឺកាលណាគេនិយាយពីកិច្ចការដែលវាអាស្រ័យគ្នាកើតឡើង ហៅថា បដិច្ចសមុប្បាទធម៌ បើគេនិយាយពីសភាវលក្ខណៈរបស់វា មិនទៀង រលត់ទៅ ហៅថា បដិច្ចសមុប្បន្នធម៌ ។ បដិច្ចសមុប្បាទធម៌ ជាហេតុ បដិច្ចសមុប្បន្នធម៌ ជាផល គឺ បដិច្ចសមុប្បាទធម៌ជាហេតុ ឲ្យកើត បដិច្ចសមុប្បន្នធម៌ជាផល រួចហើយ

---

[៩]-សុត្តន្តបិដក សំយុត្តនិកាយ និទានវគ្គ អភិសមយសំយុត្ត ៣១-៦០-៩៣

បដិច្ចសមុប្បន្នធម៌ ប្រែមកជាបដិច្ចសមុប្បាទធម៌ ជាហេតុ ឲ្យ-កើត បដិច្ចសមុប្បន្នធម៌ ជាផល តៗទៅទៀត យ៉ាងនេះ មិនមានទីបំផុត ។

២-ផលនៃការឃើញច្បាស់នូវ បដិច្ចសមុប្បាទធម៌ និង បដិច្ចសមុប្បន្នធម៌ គឺការបានសម្រេចធម៌ជាន់ខ្ពស់បំផុតហើយ ។ គេមិនមានគំនិត មិនមានសេចក្ដីសង្ស័យថា មានអញឬមិនមានអញ តើអតីតកាល អញយ៉ាងម៉េច ទៅអនាគតកាល អញយ៉ាងម៉េច បច្ចុប្បន្នកាលនេះ អញយ៉ាងម៉េច គឺគេឃើញច្បាស់ថា វាគ្រាន់តែជាសភាវធម៌ (បដិច្ចសមុប្បាទធម៌ និង បដិច្ចសមុប្បន្នធម៌ ) កើតឡើងអាស្រ័យហេតុបច្ច័យ កើតរលត់ៗ មិនមែនជាសត្វ ជាបុគ្គល យើង គេ មិនគប្បីមាន តណ្ហា ឧបាទាន អ្វីក្នុងធម៌នោះឡើយ ។

<u>សង្កេត</u> :

ក្នុងបច្ចយសូត្រនេះ មានពាក្យគប្បីសិក្សា **ធម្មដ្ឋិតតា** ការតាំងនៅនៃធម៌ **ធម្មនិយាមតា** ការកំណត់នៃធម៌ **ឥទប្បច្ចយតា** ការមាននេះជាបច្ច័យ ។ **ធម្មដ្ឋិតតា ធម្មនិយាមតា** ធ្លាប់មានក្នុងឧប្បាទសូត្រ ហើយ ចំណែក **ឥទប្បច្ចយតា** ទើបតែមានក្នុងសូត្រនេះ ដែលគេត្រូវកត់សំគាល់ជាពិសេស ។

ការតាំងនៅនៃធម៌ គឺការតាំងនៅជាធម្មតា ឬការតាំងនៅនៃច្បាប់ធម្មជាតិ ។ ការកំណត់នៃធម៌ គឺការកំណត់ជាធម្មតា ឬការកំណត់នៃច្បាប់ធម្មជាតិ ។ មិនមាននរណាអ្នកសាងទេ គឺវាមានមកជាធម្មតារបស់វា ។ ធម្មជាតិ ឬធម្មតា វាមានថ្ងៃ មានយប់ មានរដូវក្តៅ រដូវភ្លៀង រដូវទឹកសន្សើម... មនុស្ស សត្វ រុក្ខជាតិ កើតមក មាន ចាស់ ឈឺ ស្លាប់ (រលត់) ជាធម្មតា ។ល។ នេះ ជាការតាំងនៅនៃធម៌ នេះ ជាការកំណត់នៃធម៌ គឺវាមានជាធម្មតារបស់វាអញ្ចឹង មិនមានបុគ្គលណា អ្នកសាងទេ ។

ចំណែក **ឥទប្បច្ចយតា** ការមាននេះជាបច្ច័យ គឺមានអ្វី... ជាបច្ច័យ មានអ្វី.... ជាហេតុ ត្រូវនឹងពាក្យខ្មែរយើងថា ដោយហេតុ ដោយសារ ព្រោះតែ... ឧទាហរណ៍ៈ

ដោយសារភ្លៀង ដីរអិល, ដោយសារដីរអិល មនុស្សដួល, ដោយសារមនុស្សដួល ដៃបាក់, ដោយសារដៃបាក់ ទើបគេនាំយកទៅពេទ្យ ។ល។

ព្រះពុទ្ធ សំដែងថា ម្នាលភិក្ខុទាំងឡាយ **តថតា** ភាពពិត **អវិតថតា** ភាពទៀងទាត់ **អនញ្ញថតា** ភាពមិនប្រែប្រួល **ឥទប្បច្ចយតា** ភាពមាននេះជាបច្ច័យ មានក្នុងធម៌នោះឯណានេះ ហៅថា បដិច្ចសមុប្បាទធម៌ ។ នេះ បញ្ជាក់ថាក្នុងបដិច្ចសមុប្បាទ មាន ឥទប្បច្ចយតា ៕

# អរិយសាវកសូត្រ

៣*៤

១៧៨-ព្រះមានព្រះភាគ គង់នៅវត្តជេតពន ទៀបក្រុងសាវត្ថី ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អរិយសាវកអ្នកចេះដឹង មិនមានសេចក្តីត្រិះរិះយ៉ាងនេះថា កាលបើរបស់អ្វីមាន ទើបរបស់អ្វីមានហ្ន៎, របស់អ្វីកើតឡើង ព្រោះការកើតឡើងនៃរបស់អ្វីហ្ន៎, កាលបើរបស់អ្វីមាន ទើបសង្ខារទាំងឡាយមាន, កាលបើរបស់អ្វីមាន ទើបវិញ្ញាណមាន... នាមរូប... សឡាយតនៈ... ផស្សៈ... វេទនា... តណ្ហា... ឧបាទាន... ភព... ជាតិ កាលបើរបស់អ្វីមាន ទើបជរាមរណៈមាន ដូច្នេះឡើយ ។

ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង អរិយសាវកអ្នកចេះដឹង មានញាណក្នុងធម៌នោះ ព្រោះបច្ច័យដែលកើតតៗគ្នាថា កាលបើរបស់នេះមាន របស់នេះក៏មាន, របស់នេះកើតឡើង ព្រោះការកើតឡើងនៃរបស់នេះ, កាលបើអវិជ្ជាមាន សង្ខារទាំងឡាយក៏មាន, កាលបើសង្ខារទាំងឡាយមាន វិញ្ញាណក៏មាន, ។ល។ កាលបើជាតិមាន ជរាមរណៈក៏មាន ។ អរិយសាវកនោះ តែងដឹងច្បាស់ថា លោកនេះ រមែងកើតឡើងព្រមយ៉ាងនេះ ។

ម្នាលភិក្ខុទាំងឡាយ អរិយសាវកអ្នកចេះដឹង មិនមានសេចក្តីត្រិះរិះយ៉ាងនេះថា កាលបើរបស់អ្វីមិនមាន របស់អ្វីក៏មិនមាន,

របស់អ្វីរលត់ ព្រោះការរលត់នៃរបស់អ្វី, កាលបើអ្វីមិនមាន សង្ខារទាំងឡាយក៏មិនមាន, កាលបើរបស់អ្វីមិនមាន វិញ្ញាណក៏មិនមាន... នាមរូប... សឡាយតនៈ... ផស្សៈ... វេទនា... តណ្ហា... ឧបាទាន... ភព... ជាតិ, កាលបើរបស់អ្វីមិនមាន ជរាមរណៈក៏មិនមាន ដូច្នេះឡើយ ។

ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង អរិយសាវកអ្នកចេះដឹង មានញាណក្នុងធម៌នោះ ព្រោះបច្ច័យដែលកើតតៗគ្នាថា កាលបើរបស់នេះមិនមាន របស់នេះក៏មិនមាន, របស់នេះរលត់ ព្រោះការរលត់នៃរបស់នេះ, កាលបើវិញ្ញាណមិនមាន នាមរូបក៏មិនមាន, កាលបើនាមរូបមិនមាន សឡាយតនៈក៏មិនមាន ។ល។ កាលបើជាតិមិនមាន ជរាមរណៈក៏មិនមាន ។ អរិយសាវកនោះ រមែងដឹងច្បាស់យ៉ាងនេះថា លោកនេះ រមែងរលត់យ៉ាងនេះ[១០]។

## កំណត់ចំណាំ

ក្នុងព្រះសូត្រនេះ មានគោលសំខាន់ណាស់ គឺ:

**១-ឥមស្មឹ សតិ ឥទំ ហោតិ ឥមស្សុប្បាទា ឥទំ ឧប្បជ្ជតិ ។ ឥមស្មឹ សតិ** កាលបើរបស់នេះមាន **ឥទំ ហោតិ** របស់នេះក៏មាន **ឥមស្សុប្បាទា ឥទំ ឧប្បជ្ជតិ** របស់

---

[១០]-សុត្តន្តបិដក សំយុត្តនិកាយ និទានវគ្គ អភិសមយសំយុត្ត ៣១-១៧៨-១៧០

នេះកើតឡើង ព្រោះការកើតឡើងនៃរបស់នេះ ។ នេះ ហេតុកើតឡើងនៃលោក ។

២-**ឥមស្មឹ អសតិ ឥទំ ន ហោតិ ឥមស្ស និរោធា ឥទំ និរុជ្ឈតិ ៗ ឥមស្មឹ អសតិ** កាលបើរបស់នេះមិនមាន **ឥទំ ន ហោតិ** របស់នេះក៏មិនមាន **ឥមស្ស និរោធា ឥទំ និរុជ្ឈតិ** របស់នេះរលត់ ព្រោះការរលត់នៃរបស់នេះ ។ នេះ ហេតុ រលត់នៃលោក ។

ខ្ញុំសូមជម្រាបថា លោកណាៗក៏ដោយ សង្ខារលោក សត្វលោក ឱកាសលោក កាមលោក រូបលោក អរូបលោក លោករូប លោកវេទនា លោកសញ្ញា លោកសង្ខារ លោកវិញ្ញាណ លោកភ្នែក លោកត្រចៀក លោកច្រមុះ លោកអណ្តាត លោកកាយ លោកចិត្ត ។ល។ លោកអ្វីៗទៀតក៏ដោយ សុទ្ធតែកើត និង រលត់ ដោយហេតុដូចពោលហើយខាងលើនេះទាំងអស់ ៕

ខ្មែររស់ឬស្លាប់ដោយសារខ្មែរ
កែឬមិនកែ ហេតុ ឲ្យត្រូវ
បើមិនកែ ហេតុ ស្លាប់ឥឡូវ
បើកែ ហេតុ ត្រូវរស់ឡើងវិញ

# **បដិច្ចសមុប្បាទ**

# និង

# **ឥទប្បច្ចយតា**

៣✻៨

**បដិច្ចសមុប្បាទ** ធម៌អាស្រ័យគ្នាកើតឡើង **ឥទប្បច្ចយតា** ធម៌មាននេះជាបច្ច័យ ទាំង ២ នេះ ជាធម៌ជាមួយគ្នា នៅជាមួយគ្នា ជាប់ជាមួយគ្នា ប៉ុន្តែ គេវែកញែកគេនិយម បដិច្ចសមុប្បាទច្រើនជាង ។ មើលទៅ ឃើញតែ បដិច្ចសមុប្បាទ ស្តាប់ទៅឮតែ បដិច្ចសមុប្បាទ អ្វីៗ បដិច្ចសមុប្បាទ ។ ឯ ឥទប្បច្ចយតា គេមិនសូវឃើញ មិនសូវឮ មិនសូវនិយាយ ។

អ្នកប្រាជ្ញខ្លះ និយាយថា ធម៌នេះ គួរចែកជា ២ គឺ :

១-**បដិច្ចសមុប្បាទ** អវិជ្ជា ជាបច្ច័យឲ្យកើតសង្ខារ ។ល។ សំរាប់ប្រើជាមួយមនុស្ស... ព្រោះមនុស្សទើបមានអវិជ្ជា ។

២-**ឥទប្បច្ចយតា** មាននេះជាបច្ច័យ ប្រើជាមួយអ្វីក៏បាន សូម្បីអ្វីមិនមានវិញ្ញាណ ក៏ប្រើបាន ។ ឧទាហរណ៍ : កាលបើស្គរមាន បង្គែមក៏មាន ( ស្គរជាបច្ច័យឲ្យកើតបង្គែម ) កាលបើអបាយមុខមាន សេចក្តីវិនាសក៏មាន (អបាយមុខ ជាបច្ច័យឲ្យកើត សេចក្តីវិនាស) កាលបើសេចក្តីព្យាយាមមាន សេចក្តីសម្រេចក៏មាន (សេចក្តីព្យាយាម ជាបច្ច័យឲ្យកើត សេចក្តី

សម្រេច) ។ល។ បើមិនមាន ឥទប្បច្ចយតា គ្មានអ្វីកើតឡើងបានទេ ។

ព្រះពុទ្ធ បានសំដែងថា ឥទប្បច្ចយតា មានក្នុងធម៌នោះឯណា នេះហៅថា បដិច្ចសមុប្បាទ ។ ព្រះអង្គ សម្តែងច្រើនសង្កត់ធ្ងន់ បដិច្ចសមុប្បាទ ព្រោះកងទុក្ខទាំងអស់នុ៎ះកើតឡើងអាស្រ័យគ្នា តាមទ្រឹស្តី បដិច្ចសមុប្បាទ នេះ ។ ព្រះអង្គ មានព្រះហឫទ័យ ជួយរំដោះមនុស្សឲ្យរួចផុតពីកងទុក្ខទាំងអស់នុ៎ះទើបទ្រង់សម្តែងធម៌នេះ ច្រើន ។ ចំណែក ឥទប្បច្ចយតាបណ្ឌិតគប្បីយល់តាមទំនងដូចគ្នានេះចុះ ។

ព្រះពុទ្ធ មិនបានអនុញ្ញាត ទាំងមិនបានហាមឃាត់ការបែងចែកធម៌នេះជាពីរទេ បើយើងពិចារណាម៉ត់ចត់ហើយ ឃើញមិនមានទំនាស់ និង ជាការសមគួរផង ការចែកជាពីររបស់យើងទុកជាការត្រឹមត្រូវហើយ ។

ខ្ញុំ សូមបញ្ជាក់ថា ព្រះពុទ្ធបរមគ្រូរបស់យើង ជាអ្នកបានរកឃើញ បដិច្ចសមុប្បាទ និង ឥទប្បច្ចយតា ដែលជាទ្រឹស្តីមួយដ៏ប្រសើបំផុតនេះ ៕

# សារីបុត្រ និង មោគ្គល្លាន

នៅជិតក្រុងរាជគ្រឹះ មានស្រុក ២ គឺ : ឧបតិស្សគ្រាម ១ កោលិតគ្រាម ១ ។ ឧបតិស្សគ្រាម ជាស្រុកកំណើតរបស់សារីបុត្រ ។ កោលិតគ្រាម ជាស្រុកកំណើតរបស់មោគ្គល្លាន ។

## សារីបុត្រមានឈ្មោះ ២ គឺ :

១-គេដាក់ឈ្មោះថា ឧបតិស្សៈ ព្រោះជាកូននៃត្រកូលដ៏ចម្បងជាងគេក្នុង ឧបតិស្សគ្រាម ។

២-គេហៅថា សារីបុត្រ ព្រោះជាកូននៃនាងព្រាហ្មណីឈ្មោះ សារី ។

## មោគ្គល្លានមានឈ្មោះ ២ គឺ :

១-គេដាក់ឈ្មោះថា កោលិតៈ ព្រោះជាកូននៃត្រកូលដ៏ចម្បងជាងគេក្នុង កោលិតគ្រាម ។

២-គេហៅថា មោគ្គល្លាន ព្រោះជាកូននៃនាងព្រាហ្មណីឈ្មោះ មោគ្គល្លី ។

ត្រកូលទាំងពីរនេះ ជាត្រកូលស្តុកស្តម្ភ រាប់អានជិតដិតស្និតស្នាលគ្នាមក ៧ ជួរមនុស្សហើយ ។ សារីបុត្រ និង មោគ្គល្លាន ជាមិត្រសម្លាញ់គ្នា តាំងពីនៅក្មេង... លុះពេញវ័យហើយ ពេល

ចេញដើរលេងកំសាន្តម្តងៗ មានគ្រែស្នែង រថ សុទ្ធសឹងតែមាស... និងមានបរិវារ ៥០០ ម្នាក់ៗ ។ មហោស្រពលេងនៅទីណា សារីបុត្រ និង មោគ្គល្លាន ទៅទីនោះ ពេលខ្លះក៏ស្រណោះស្រណោក ពេលខ្លះក៏សើចក្អាកក្អាយ ពេលខ្លះសប្បាយរីករាយខ្លាំងរហូតដល់មានឲ្យជារង្វាន់លើកទឹកចិត្ត ដល់អ្នកសម្តែងផងក៏មាន ។

មានម្តងនោះ ពេលមហោស្រពកំពុងលេង ហេតុតែបុណ្យមកដល់ កុសលមកជួយ សារីបុត្រកើតគំនិតល្អឡើងថា ដូចជាអត់មានអ្វី គួរឲ្យចង់មើល ចង់ស្តាប់ គួរឲ្យសប្បាយរីករាយសោះ អ្នកលេងមហោស្រពក្តី អ្នកមើល អ្នកស្តាប់ក្តី មិនដល់ ១០០ ឆ្នាំផង អស់តម្លៃ អត់ន័យអ្វីទាំងអស់... យើងគួរតែនាំគ្នាស្វែងរកធម៌វិញប្រសើរជាង ។ ថ្ងៃហ្នឹង សារីបុត្រ អត់សើច អត់-សប្បាយ ដូចថ្ងៃមុនៗទេ បែរជាស្រងូតស្រងាត់ សង្វេគទៅវិញ។

លុះមហោស្រពឈប់លេង មោគ្គល្លាន សួរសារីបុត្រថា ថ្ងៃនេះ ខ្ញុំមើលទៅមិនឃើញលោករីករាយសប្បាយដូចថ្ងៃមុនៗសោះ ? សារីបុត្រ ឆ្លើយរៀបរាប់ពីគំនិតរបស់ខ្លួនប្រាប់មោគ្គល្លាន ។ មោគ្គល្លាន ក៏និយាយឡើងថា ខ្ញុំថ្ងៃហ្នឹង ក៏មានគំនិតដូចលោកដែរ ។ អើ ! បើដូច្នោះ យើងត្រូវនាំគ្នាស្វែងរកមោក្ខធម៌វិញ ។

# សារីបុត្រ មោគ្គល្លាន ស្វែងរកធម៌

៣*៧

ក្នុងក្រុងរាជគ្រឹះ មានបរិព្វាជក ជាគ្រូធំម្នាក់ឈ្មោះ សញ្ជ័យ ប្រៀនប្រដៅសិស្សជាច្រើននៅទីនោះ ។ សារីបុត្រ និង មោគ្គល្លាន បានចូលទៅប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសំណាក់នៃ អាចារ្យសញ្ជ័យនោះឯង ។ អ្នកទាំងពីរនោះ បានសិក្សាបដិបត្តិ ត្រឹមពីរបីថ្ងៃប៉ុណ្ណោះ ចេះចប់វិជ្ជាអស់ អត់មានវិជ្ជាអ្វីតទៅទៀត ទាំងមិនបានឃើញសម្រេចធម៌អ្វីគួរជាទីពេញចិត្តសោះឡើយ ទើប ប្រឹក្សាគ្នា គិតចេញស្វែងរកធម៌បន្តទៅទៀត និងបានធ្វើកតិកាគ្នា ថា បើនរណាបានសម្រេចអមតធម៌មុន ត្រូវតែប្រាប់ដំណឹងដល់ ម្នាក់ទៀតផង ។

ជួនជាពេលនោះ ព្រះដ៏ទ្រង់យស សម្មាសម្ពុទ្ធបរមគ្រូ របស់យើង ស្ដេចនិមន្ត ប្រកាសផ្សាយពុទ្ធសាសនា ចូលដល់ក្រុង រាជគ្រឹះហើយ ។ ថ្ងៃមួយ សារីបុត្របានឃើញព្រះអស្សជិ កំពុង និមន្តបិណ្ឌបាត ប្រកបដោយចរិយាស្រគត់ស្រគំ សមរម្យគួរជាទី ជ្រះថ្លាក្រៃពេក... បានសួរថា លោកម្ចាស់បួសឧទ្ទិសបុគ្គលណា? នរណាជាគ្រូរបស់ព្រះអង្គ ? គ្រូរបស់ព្រះអង្គ ប្រៀនប្រដៅយ៉ាង ម៉េចខ្លះ ? ព្រះអស្សជិ តបថា អាត្មាបួស ឧទ្ទិសព្រះសម្មាសម្ពុទ្ធ ព្រះសមណគោតម សម្មាសម្ពុទ្ធ ជាគ្រូរបស់អាត្មា អាត្មា ទើប

នឹងបួសថ្មីៗ សម្ដែងបានតែធម៌ខ្លីៗដូចតទៅនេះ -

**យេ ធម្មា ហេតុប្បភវា តេសំ ហេតុំ តថាគតោ**
**តេសញ្ច យោ និរោធោ ឯវំវាទី មហាសមណោ ។**

ធម៌ទាំងឡាយឯណា មានហេតុជាដែនកើត (កើតអំពីហេតុ) ព្រះតថាគត សម្ដែងហេតុ (កើត) នៃធម៌ទាំងអស់នោះ និងហេតុរលត់នៃធម៌ទាំងអស់នោះ ព្រះមហាសមណៈ មានប្រក្រតីប្រៀនប្រដៅយ៉ាងនេះ ។

កាលបានស្ដាប់ ធម្មបរិយាយនេះ ភ្នែកធម៌ (សោតាបត្តិ-មគ្គញ្ញាណ) ប្រាសចាកធូលី ប្រាសចាកមន្ទិល ថា ធម្មជាតឯណានីមួយ មានការកើតឡើងជាធម្មតា ធម្មជាតនោះទាំងអស់ មានការរលត់ទៅជាធម្មតា បានកើតឡើងដល់ បរិព្វាជកសារីបុត្រថា –

**ឯសេវ ធម្មោ យទិ តាវទេវ បច្ចព្យថ បទមសោកំ**
**អទិដ្ឋំ អព្ភតីតំ ពហុកេហិ កប្បនហុតេហិ ។**

ធម៌នេះឯង មានក៏ត្រឹមតែប៉ុណ្ណឹង លោកម្ចាស់ចាក់ធ្លុះនូវបទដែលមិនមានសេចក្ដីសោក បទដែលមិនមានសេចក្ដីសោកនេះ យើងខ្ញុំមិនដែលបានឃើញ កន្លងទៅហើយ ច្រើនម៉ឺនកប្ប ។

គ្រានោះ ព្រះសារីបុត្រ ចូលទៅរកមោគ្គល្លាន ។ មោគ្គល្លាន ឃើញព្រះសារីបុត្រមកពីចម្ងាយ មានមុខស្រស់បស់

ផ្លូវផង់ប្លែកធម្មតា បានពោលថា លោកប្រហែលជាបានសម្រេចអមតធម៌ហើយ ! ព្រះសារីបុត្រ ឆ្លើយ អើ ! ខ្ញុំបានសម្រេចអមតធម៌ហើយ ។ មោគ្គល្លាន សួរ... ព្រះសារីបុត្រ ឆ្លើយរៀបរាប់រឿងសព្វគ្រប់ប្រាប់... លុះបានស្តាប់ធម្មបរិយាយនេះហើយ ធម្មចក្ខុ (ភ្នែកធម៌) ក៏កើតឡើងដល់ព្រះមោគ្គល្លានដូចជាព្រះសារីបុត្រ ដូច្នោះដែរ ។

## ព្រះសារីបុត្រ ព្រះមោគ្គល្លាន ចេញបួស

ព្រះមោគ្គល្លាន បបួលព្រះសារីបុត្រ ទៅគាល់ព្រះសម្មាសម្ពុទ្ធ ។ ព្រះសារីបុត្រ ពោលថា បរិព្វាជក ២៥០ នាក់ មកបដិបត្តិធម៌ ក្នុងទីនេះ ព្រោះតែយើង បើយើងទៅទីណា ត្រូវតែប្រាប់អ្នកទាំងអស់នោះផង ។ បរិព្វាជកទាំងអស់នោះ លុះបានស្តាប់ហើយ ឆ្លើយថា លោកទៅបដិបត្តិធម៌ក្នុងទីណា យើងខ្ញុំក៏ទៅ ក្នុងទីនោះដែរ ។ បន្ទាប់មក ព្រះសារីបុត្រ និងព្រះមោគ្គល្លាន ទៅបបួលអាចារ្យសញ្ជ័យ ទៅគាល់ព្រះសម្មាសម្ពុទ្ធ ជាមួយគ្នា ។ អាចារ្យសញ្ជ័យ ពោលថា កុំទៅអីយើងទាំងបីនាក់រួមគ្នាគ្រប់គ្រងនៅទីនេះបានហើយ ។ គ្រានោះព្រះសារីបុត្រ និង ព្រះមោគ្គល្លាន នាំបរិព្វាជក ២៥០ នាក់ទៅកាន់វត្តវេឡុវ័ន ។ ចំណែក អាចារ្យសញ្ជ័យ ក្តៅក្រហាយក្អួតឈាមក្នុងទីនោះឯង ។

ព្រះមានព្រះភាគ បានទតឃើញព្រះសារីបុត្រនិងព្រះមោគល្លាន កំពុងដើរមកអំពីចម្ងាយ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សម្លាញ់ ២ នាក់នោះ ឈ្មោះកោលិតៈ ១ ឈ្មោះឧបតិស្សៈ ១ នឹងមកដល់ឥឡូវនេះហើយ ហ្នឹងហើយជាគូនៃសាវកដ៏ប្រសើររបស់ តថាគត ។

គ្រានោះ ព្រះសារីបុត្រ និង ព្រះមោគ្គល្លាន ចូលទៅគាល់ព្រះមានព្រះភាគ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន យើងខ្ញុំគប្បីបានបព្វជ្ជា ឧបសម្បទា ក្នុងសំណាក់នៃព្រះមានព្រះភាគ ។ ព្រះមានព្រះភាគ ត្រាស់ថា **ឯថ ភិក្ខវោ** អ្នកទាំងឡាយ ចូរជាភិក្ខុចុះ ធម៌តថាគត សម្តែងល្អហើយ អ្នកទាំងឡាយ ចូរប្រព្រឹត្តព្រហ្មចរិយធម៌ ដើម្បីធ្វើនូវទីបំផុតនៃទុក្ខ (គឺព្រះនិព្វាន) ដោយប្រពៃចុះ ។ ព្រះពុទ្ធដីកានេះឯង ជាឧបសម្បទា របស់លោកដ៏មានអាយុទាំងនោះ[១១] ។

## សម្លាញ់ល្អ កម្រមាន

---

[១១]-វិនយបិដក មហាវគ្គ ៦-៦៤-១២០

## កំណត់ចំណាំ

១-ធម៌ (អ្វីៗ) ទាំងឡាយទាំងពួង សុទ្ធតែមានហេតុ គឺកើតមកពីហេតុ ។ បើមិនមានហេតុ (អស់ហេតុ) មិនមានកើត (រលត់) ។ ល្អ កើតមកពីហេតុល្អ ។ អាក្រក់ កើតមកពីហេតុអាក្រក់, សុខ កើតមកពីហេតុដែលនាំឲ្យសុខ, ទុក្ខ កើតមកពីហេតុដែលនាំឲ្យទុក្ខ... ធម៌ទាំងអស់នោះ មិនមានអ្នកសាង មិនមានអ្នកបង្កើតទេ គឺហេតុហ្នឹងឯង ជាអ្នកសាង ជាអ្នកបង្កើត ។ ដូច្នេះ ចង់បានអ្វី ? ចំណេះ វិជ្ជា ទ្រព្យសម្បត្តិ សុខ ចំរើន... ត្រូវរកហេតុ ត្រូវសាងឲ្យចំហេតុ ធ្វើឲ្យចំហេតុ កែលំអឲ្យចំហេតុ ។ ព្រះពុទ្ធ បរមគ្រូយើង មានប្រក្រតីប្រៀនប្រដៅឲ្យស្គាល់ហេតុ ហេតុកើត ហេតុរលត់... ហើយដោះស្រាយបញ្ហាឲ្យចំហេតុនោះៗ ។

២-អ្នកមានបញ្ញា មិនចាំបាច់ស្តាប់ច្រើនទេ ស្តាប់ត្រឹមតែពាក្យ ១ ម៉ាត់ (គឺហេតុប៉ុណ្ណឹង) អាចធ្វើប្រយោជន៍បាន ឬ អាចសម្រេចរហូតដល់ មគ្គ ផល បាន ។

៣-ធម៌មានត្រឹមតែប៉ុណ្ណឹង គឺមានត្រឹមតែហេតុ កើតមកពីហេតុ មានហេតុ ទើបមានផល ។ បើស្គាល់ហេតុ ធ្វើហេតុឲ្យត្រូវហើយ គឺវាចប់ ។

បទមិនមានសេចក្តីសោក គឺមិនមានទុក្ខ ឬ ព្រះនិព្វាន ។

លោកម្ចាស់ (ព្រះអរិយៈ) ចាក់ធ្លុះ (សម្រេច) បទមិនមានសេចក្តីសោកនោះ ប៉ុន្តែ បទមិនមានសេចក្តីសោកនោះ ពួកយើងខ្ញុំ (បុថុជ្ជន) មិនដែលឃើញ គឺមិនដែលបានចាក់ធ្លុះ កន្លងទៅហើយ ច្រើនម៉ឺនកប្ប ។ ដូច្នេះ ត្រូវតែប្រញាប់ស្វែងរក បទមិនមានសេចក្តីសោកនោះឲ្យឃើញ ទាន់មានឱកាសល្អ ៕

## អរិយសច្ច ៤

៙✵៚

១-**ទុក្ខសច្ចៈ** ទុក្ខ ១២ កង គឺ ជាតិ ជរា មរណៈ ។ល។ ពោលដោយខ្លី គឺ ខន្ធ ៥ (ឧបាទានក្ខន្ធ ៥) ។

២-**សមុទយសច្ចៈ** កាមតណ្ហា ចំណង់ក្នុងកាមគុណ ភវតណ្ហា ចំណង់ក្នុងភព វិភវតណ្ហា ចំណង់ក្នុងវិភព ។

៣-**និរោធសច្ចៈ** រំលត់តណ្ហាទាំង ៣ នោះ ។ តណ្ហាកើតក្នុងរូប រំលត់តណ្ហាកើតក្នុងរូបនោះ តណ្ហាកើតក្នុងសម្លេង ។ល។ រំលត់តណ្ហាកើតក្នុងសម្លេងនោះ ។ល។

៤-**មគ្គសច្ចៈ** មគ្គប្រកបដោយអង្គ ៨ មានសម្មាទិដ្ឋិ ការយល់ឃើញត្រូវជាដើម ។

អរិយសច្ច ៤ ជាហេតុ ផល គឺ សមុទយសច្ច ជាហេតុ ទុក្ខសច្ច ជាផល, មគ្គសច្ច ជាហេតុ និរោធសច្ច ជាផល ។ អរិយសច្ច ៤ នេះ ជាឥទប្បច្ចយតា ៕

# សរុបសេចក្ដី

៣✵៧

បដិច្ចសមុប្បាទ ធម៌អាស្រ័យគ្នាកើតឡើងព្រម ក៏និយាយពីហេតុ ។ ឥទប្បច្ចយតា ធម៌មាននេះជាបច្ច័យ ក៏និយាយពីហេតុ ។ ព្រះអស្សជិ សម្ដែងធម៌ ប្រោសព្រះសារីបុត្រ ក៏និយាយពីហេតុ ។ អរិយសច្ច ៤ ក៏និយាយពីហេតុ ។ល។ អ្វីៗសុទ្ធតែមានហេតុ កើតឡើងអាស្រ័យហេតុទាំងអស់ ។ ដូច្នេះ បើគេត្រូវការដោះស្រាយបញ្ហាអ្វីមួយ គេត្រូវតែសិក្សារកហេតុជាមុនសិន បញ្ហាអ្វី ? មកពីអ្វី ? ដើម្បីអ្វី ? ត្រូវធ្វើអ្វី (ត្រូវធ្វើដូចម្ដេច ?) គេគប្បីធ្វើឲ្យត្រូវចំណុច ឬ កែលំអ ឬ កែកំហុស ឲ្យត្រូវចំហេតុ ធ្វើហូរហែតែប៉ុណ្ណឹង អ្វីៗវានឹងចាប់ធូរស្រាល រហូតបានសម្រេចជាស្ថាពរ ពិតពុំខាន ។

## បញ្ហានានា

១-បញ្ហាបុគ្គល :

អ្នកក្រមកពីអ្វី ? : មកពី ខ្ជិល

អ្នកក្រមកពីអ្វី ? : មកពី មិនចេះទុកដាក់ទ្រព្យសម្បត្តិ

អ្នកក្រមកពីអ្វី ? : មកពី ចាយវាយខ្ជះខ្ជាយ

អ្នកក្រមកពីអ្វី ? : មកពី សេពគប់មិត្រអាក្រក់

អ្នកក្រមកពីអ្វី ? : មកពី លេងល្បែងអបាយមុខ។ល។

២-បញ្ហាសង្គម :

អ្នកក្រមកពីអ្វី ?: មកពី មិនបានរៀនសូត្រ
អ្នកក្រមកពីអ្វី ?: មកពី មិនមានដីធ្លី ពូជធារ
អ្នកក្រមកពីអ្វី ?: មកពី មិនមានទីផ្សារសម្រាប់លក់
អ្នកក្រមកពីអ្វី ?: មកពី មិនមានការជួយឧបត្ថម្ភ
អ្នកក្រមកពីអ្វី ?: មកពី មិនមានថវិកាឡូខ្ចី
អ្នកក្រមកពីអ្វី ?: មកពី មិនមានការលើកទឹកចិត្ត

។ល។

៣-បញ្ហាជាតិ :

អ្នកក្រមកពីអ្វី ?: មកពី នាម៉ឺនស្រឡាញ់ខ្លួន(បក្ស)ជាង
ស្រឡាញ់ជាតិ
អ្នកក្រមកពីអ្វី ?: មកពី នាម៉ឺន រឹបជាន់រាស្ត្រ
អ្នកក្រមកពីអ្វី ?: មកពី នាម៉ឺន ពុករលួយ
អ្នកក្រមកពីអ្វី ?: មកពី នាម៉ឺន លួចសម្បត្តិជាតិ
អ្នកក្រមកពីអ្វី ?: មកពី នាម៉ឺន ចូលដៃបើកល្បែងស៊ីសង
អ្នកក្រមកពីអ្វី ?: មកពី នាម៉ឺន ចូលដៃរត់គ្រឿងញៀន
អ្នកក្រមកពីអ្វី ?: មកពី នាម៉ឺន ចូលដៃរត់ពន្ធផ្សេងៗ

។ល។

បើគេដោះស្រាយហេតុ ឬ កែលំអ កែកំហុស ដូចបាន ជម្រាបមកខ្លីៗនេះ ចំនួនអ្នកក្រនឹងថយចុះជាលំដាប់ ប្រជាជន និង ប្រទេសជាតិ នឹងបានចំរើន រុងរឿង ឡើងវិញ ពិតពុំខាន ។

## រឿងគួរឱ្យអាម៉ាស់

៙

មានខ្មែរខ្លះ និយាយថា រឿងខ្មែរ កែមិនឡើងទេ... ខ្មែរធ្វើធំមិនកើត ត្រួតត្រាគ្នាឯងមិនកើត បានត្រឹមតែធ្វើខ្ញុំគេ...។ ខ្ញុំយល់ថា គំនិតនេះ ជាគំនិតបរទេស គេរំលាយខ្មែរ ។ ខ្មែរកញ្ជះគេ រើសយកគំនិត យកពាក្យនេះ មកគិត មកនិយាយ ... ខ្មែរយើង កុំសេពគប់ កុំឲ្យតម្លៃ ខ្មែរកញ្ជះគេនេះ ។ កូនខ្មែរពិតប្រាកដ សិស្សព្រះពុទ្ធពិតប្រាកដ មិនគប្បីមានគំនិត បែបនេះទេ ព្រោះខ្មែរយើងធ្លាប់ធ្វើធំពីដើម មានស្នាដៃរហូតដល់សព្វថ្ងៃនេះផង និង ព្រោះវាមានទំនាស់នឹងពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធផង ។

## មនុស្សជាសត្វហ្វឹកហាត់បាន

---

មនុស្សជាសត្វហ្វឹកហាត់បាន ជាសត្វកែលំអបាន ជាសត្វ

កសាងខ្លួនបាន ។ មនុស្សខិលខូច អាចកែប្រែទៅជាមនុស្សល្អ មនុស្សក្រីក្រ អាចកែប្រែទៅជាអ្នកមាន មនុស្សបុថុជ្ជន អាចកែប្រែទៅជា ព្រះអរិយៈ ឬ ជាព្រះពុទ្ធបាន ។ តើគេកែប្រែបានដោយសារអ្វី ? ដោយសារកែប្រែហេតុ គឺឈប់ធ្វើហេតុអាក្រក់ ហើយខំកសាងតែហេតុល្អ... ។ ព្រោះហេតុដូច្នោះ ទើបព្រះទ្រង់យស ប្រៀនប្រដៅឲ្យស្គាល់ហេតុ... ។ ព្រះពុទ្ធបរមគ្រូរបស់យើង ជាអ្នកប្រៀនប្រដៅមនុស្ស និង ទេវតា រកបុគ្គលណាប្រៀបស្មើគ្មាន ៕

## ព្រះសង្ឃខ្មែរយើងគិតយ៉ាងម៉េចដែរ

អ្នកខ្លះ គេគិតរត់ចោលស្រុក គេថាកុំនៅស្រុកមនុស្សក្ដៅក្រហាយណាស់... ស្ដាយអីទ្រព្យប៉ុណ្ណឹង ទៅ កុំស្ដាយ... ទៅស្ថានសួគ៌ ទៅនិព្វាន សុខសប្បាយច្រើនជាងនេះឆ្ងាយណាស់ ធៀបគ្នាមិនបានទេ ។ មួយថ្ងៃៗ គេឃោសនា តែរឿងស្ថានសួគ៌ រឿងនិព្វាន ចំណែកស្រុកមនុស្ស គេបំភ្លេចចោលហើយ គេនិយាយបន្តិចបន្តួចយកតែ... ប៉ុណ្ណោះ ។

តើព្រះសង្ឃខ្មែរយើងគិតយ៉ាងម៉េចដែរ ? ថ្ងៃខ្លះ តាមរូបថត ឃើញសម្ដេច ចេញមកប្រឈមមុខគ្នា ក្ងស់៤,៥ មិនដឹងជា

អង្គណាធំជាងអង្គណា អញក៏ក្ងស់ ឯងក៏ក្ងស់... ។ ខ្ញុំមិនដឹងមានពាក្យអីនិយាយ បើវាអស្ចារ្យយ៉ាងហ្នឹង ! ខ្ញុំជឿថា ព្រះសង្ឃវង្វេងអាចមានខ្លះ ប៉ុន្តែ ព្រះសង្ឃដែលមានសតិ សម្បជញ្ញៈគង់នៅមានខ្លះដែរ ។ តើព្រះសង្ឃខ្មែរយើង គិតយ៉ាងម៉េច ?

ខ្ញុំសូមជម្រាបថា ព្រះសង្ឃបរទេស គេចង់នាំគ្នាទៅស្ថានសួគ៌ ចង់ដល់ព្រះនិព្វាន ដូចយើងដែរ ប៉ុន្តែ គេមិនគិតរត់ចោលស្រុកទេ ។ គេថា គេទៅស្ថានសួគ៌ ទៅនិព្វាន បែបសន្សឹមៗ ព្រោះស្រុកនោះឆ្ងាយណាស់... យើងត្រូវជួយមនុស្សអ្នកស្រុកយើងឲ្យមានបាយស៊ី ឲ្យមានកម្លាំងពលំ មានស្បែកជើងពាក់ មានផ្លូវថ្នល់ មានយានជំនិះ ដើម្បីធ្វើដំណើរទៅស្ថានសួគ៌ទៅនិព្វាន ។ គេប្រឹងប្រែងជួយប្រទេសជាតិ និង ប្រជាជនរបស់គេ ច្រើនណាស់ ។

ប្រទេសជាតិ កំពុងមានបញ្ហា ប្រជាជន កំពុងក្រីក្រទុក្ខលំបាក អ្នកនាំគ្នាសប្បាយ ហ៊ឺហា ស្រា ស្រី... ក្បែរមាត់រណ្តៅមរណៈ មិនមែនជាអ្នកប្រាជ្ញ មិនមែនជាអ្នកស្រឡាញ់ជាតិមាតុភូមិទេ ។ អ្នកនាំគ្នារត់ចោលស្រុក ទៅស្វែងរកសុខក្នុងស្ថានសួគ៌ មិនសមគួរជាអ្នកសាសនាពិតប្រាកដទេ ។ ឯអ្នកចំរើនវិបស្សនា ឧបេក្ខា ខុសកាលៈ ទេសៈ ឥតបើគិត ក៏មិនមែនជាបណ្ឌិត ពិតប្រាកដដែរ ។

ខ្ញុំយល់ថា យើងត្រូវនាំគ្នាសាងបារមី ឲ្យគគ្រឹកគគ្រេង ជួយប្រទេសជាតិ ជួយប្រជាជនយើង ។ នរណាមានទ្រព្យ លះបង់ទ្រព្យ, នរណាមានចំណេះ លះបង់ចំណេះ, នរណាមាន កម្លាំង លះបង់កម្លាំង, លះបង់អ្វីៗ សូម្បីជីវិត ជួយជាតិ ជួយ ប្រជាជន ឲ្យរួចឲ្យរស់សុខសាន្ត បានសប្បាយផង ។ សុខ សប្បាយ ឥឡូវហ្នឹង ជាតិហ្នឹង មិនមែនចាំសុខសប្បាយក្នុងស្ថាន សួគ៌ ជាតិមុខទេ ៕

ទុក្ខចំពោះមុខមិនដោះស្រាយ
នាំគ្នាសប្បាយថាបានសុខ
ខ្វះគិតនាំគ្នារត់ចោលស្រុក
តើគួរចាត់ទុកគេយ៉ាងម៉េច ៕

# លោកអ្នកសប្បុរស ដែលបានជួយឧបត្ថម្ភការបោះពុម្ព

| | | |
|---|---|---|
| ១- | ឧបាសិកា ស៊ីសុវត្ថិ ក្រិត្យនារី | ២០ € |
| ២- | ឧបាសិកា គុល ទូច | ៥០ € |
| ៣- | ឧបាសិកា នេត្រ គួន | ២០ € |
| ៤- | ឧបាសិកា ឡាយ រ៉ុ | ៤០ € |
| ៥- | ឧបាសិកា ឈា ឡេងហាក់ | ២០ € |
| ៦- | ឧបាសក ណៃ ហួរ | ២០ € |
| ៧- | ឧបាសក ទា ឡឹកឆាយ | ៥០ € |
| ៨- | ឧបាសក ទេស ឆ័ន្ទ ឧបាសិកា យន់ ផាត់ | ៥០ € |
| ៩- | ឧបាសក សី សួម ឧបាសិកា ចក់ ញ៉ឹយ | ៥០ € |
| ១០- | ឧបាសក តាន់ ណាំ ឧបាសិកា លិម ឆេងអ៊ី | ៥០ $ |
| ១១- | ឧបាសិកា ម៉ា វណ្ណា និង បុត្រធីតា | ២០ € |
| ១២- | ឧបាសិកា កឹម ស្លូផន និង កូនប្រុសស្រី | ២០ € |
| ១៣- | ឧបាសិកា អាត អេង និង បុត្រ | ២០ € |
| ១៤- | ឧបាសិកា ឃី អេងឡាំ | ២០ € |
| ១៥- | ឧបាសិកា ពៅ គាត ស្វរី | ២០ € |
| ១៦- | ឧបាសិកា ឃក់ លាន | ២០ € |
| ១៧- | លោក ណុប ពុទ្ធីរ និង គ្រួសារ | ២០ € |

| | |
|---|---|
| ១៨-លោក ខៀវ ឡេង និង ភរិយា | ២០ € |
| ១៩-លោក ខៀវ រដ្ឋា | ២០ € |
| ២០-លោក ង៉ី ហុក និង ភរិយា | ២០ € |
| ២១-លោកស្រី ឡោត គិរីកញ្ញា និង អេឌ័រ | ៥០ € |
| ២២-លោក និង លោកស្រី ផាយ ភ៊ន | ៤០ € |
| ២៣-លោកស្រី ប៊ុន ហ៊ុនគី | ២០ € |
| ២៤-អាចារ្យ មិន ធូ ឧបាសិកា តាំង វួចហ៉ៅ | ២០ € |
| ២៥-អ្នកស្រី គីម មួយ | ២០ € |
| ២៦-លោក ដារ៉ា | ២០ € |
| ២៧-ឧបាសិកា មួន សារ៉ាត់ និង កូនចៅ | ៤០ € |
| ២៨-ឧបាសិកា ទី វណ្ណហង្ស | ១៥ € |
| ២៩-ឧបាសិកា តេង សម្បត្តិ | ២០ € |
| ៣០-ឧបាសិកា ប៊ុន ហ៊ុលឃុត | ១៥ € |
| ៣១-ឧបាសិកា ជាវ អូន | ៣០ € |
| ៣២-ឧបាសិកា ទា គីមលី | ២០ € |
| ៣៣-ឧបាសិកា ទា គីមលន់ | ២០ € |
| ៣៤-អ្នកស្រី ត្រាន់ ផូ | ៥០ € |
| ៣៥-លោក ពេជ្រ ប៊ុន និង ភរិយា | ៤០ € |
| ៣៦-លោក ស្លួង ណារឿន និង ភរិយា | ២០ € |

៣៧-លោក ផ្លូន ទីម អ្នកស្រី ទិត ពៅ ២០ €

៣៨-អ្នកស្រី សេហ្គា ឡី និង កូនចៅ ២០ $

៣៩-អ្នកស្រី អ៊ូច សុខា ចន្ទា ៣០ €

៤០-ឧបាសិកា អៀន សៀប ១០ €

៤១-Mr et Mme Hang François និង បុត្រ ៣០ €

៤២-លោក ចៅ ហៃ ៥០ €

៤៣-លោក ជី នុ ម៉ា និង ភរិយា ៥០ €

៤៤-លោក អ៊ុន សាវេន និង ភរិយា ២០ €

៤៥-ឧបាសិកា ស្លួស សុភាព ២០ €

៤៦-ឧបាសិកា ចាន់ ហឿន និង បុត្រធីតា ១០០ $

៤៧-ឧបាសិកា ឡាយ សេង ហាក់ ១០ €

៤៨-លោក ទេព ប៊ុនថាក់ណា លោកស្រី ប៊ុក ម៉ូរ៉ានី ៣០ €

៤៩-លោកស្រី យិន មុំ ២០ €

៥០-លោក លីម ហ៊ុយគៀង អ្នកស្រី ម៉ៅ ទៀង ៥០ $

៥១-ឧបាសិកា នៅ ទាវខេង និង បុត្រធីតា ២០ €

៥២-ឧបាសិកា ណៃម លិម អ៊ាន ២០ €

៥៣-ឧបាសិកា ណៃម លិម អ៊ិន ២០ €

៥៤-ឧបាសិកា អ៊ឹង អាង ២០ €

៥៥-ឧបាសិកា អៀង ហុង ១៥ €

៥៦-ឧបាសិកា ឃិន ហុកទីវ ១៥ €

៥៧-ឧបាសិកា សុត សុផានី ១៥ €

៥៨-ឧបាសិកា សៀប គីមហ៊ាង ១៥ €

៥៩-ឧបាសិកា ផូ ម៉ាក់ ១៥ €

៦០-ឧបាសិកា តាំង អ៊ុម ១៥ €

៦១-ឧបាសិកា អ៊ុំ យន ១៥ €

៦២-លោក និង លោកស្រី ស៊ាម ហ៊ុច ១៥ €

៦៣-ឧបាសក ឡៅ ហេង ឧបាសិកា តាន់ សាយយុត ១៥ €

៦៤-អ្នកស្រី ឡៅ សាយឃីម ១៥ €

៦៥-អ្នកស្រី ជីប ហុង យេន ១៥ €

៦៦-លោក ផុង ហុងកៅ អ្នកស្រី ឡៅ ហុងឡាយ ១៥ €

៦៧-អ្នកស្រី ឡៅ ហុងស៊ីម និង បុត្រធីតា ១៥ €

៦៨-ផុង សូនីថា និង ស៊ុន ណារេត ១៥ €

៦៩-ឧបាសិកា ញ៉ឹក សាយ៉ាន់ ១៥ €

៧០-លោក ស៊ីម៉ុង ភរិយា និង កូន ១០ €

៧១-Mr In Dana ៥ €

៧២-Mr In Dano ៥ €

៧៣-Mr In Danee ៥ €

៧៤-Mme In Mada ៥ €

៧៥-Mme Sevorine ៥ €

៧៦-Mme My ៥ €

៧៧-Mme Sitho ៥ €

៧៨-តា គុំហុំ និង ភរិយា ៥ €

យើងខ្ញុំ សូមឧទ្ទិសចំណែកបុណ្យកុសលនេះ ចំពោះលោកអ្នក ដ៏មានគុណទាំងឡាយ មានមាតាបិតា ជីដូនជីតា គ្រូឧបជ្ឈាយាចារ្យ និង ញាតិកាសាលោហិត មិត្រសំឡាញ់ជាដើម ។ សូមលោក អ្នក ដ៏មានគុណទាំងឡាយជាដើមនោះ អនុមោទនា ចំពោះបុណ្យកុសលនេះ ហើយទទួលយកនូវឥដ្ឋមនុញ្ញផល ជាទីគាប់ចិត្ត កុំបីអាក់ខានឡើយ ៕

វត្តពោធិវង្ស

ប្រទេសបារាំង

101, Boulevard de la République
77420 Champs sur Marne
Tél : 01 60 06 44 98
01 64 62 17 41

## ធម៌ទាំងឡាយកើតពីហេតុ

៣✵៧

ធម៌ទាំងឡាយមានដែនកើត គឺហេតុ

រលត់ច្បាស់ក្រឡែតអស់ហេតុហើយ

បានទុក្ខបានសុខសាន្តឥតខានឡើយ

ដោយសារហេតុនេះហើយជាអ្នកសាង ។

ដូច្នេះយើងត្រូវធ្វើតែហេតុល្អ

នាំសុខសាន្តបវរជាតំណាង

ហេតុអាក្រក់នាំទុក្ខជាភស្តុតាង

យើងគេចកែកុំសាងវាឲ្យសោះ ។

ទៅស្ថានសួគ៌និព្វានដោយសារហេតុ

ទានសីលខ្ពស់ត្រដែតហេតុទាំងនោះ

ទៅនរកប្រេតខេត្តដែនអប្បយស

ព្រោះហេតុអាក្រក់នោះ ឆក់ លួច ប្លន់ ។

ជាប់គុកជាប់ច្រវាក់គេចាក់កាប់

វាយដំបាញ់សម្លាប់ឃើញទាន់ហន់

ព្រោះហេតុនោះហើយព្រះភគវ័ន្ត

ប្រោសសត្វយ៉ាងរួសរាន់ ឲ្យស្គាល់ហេតុ ៕